Unofficial Translation

# ចំណុចសំខាន់ៗនៃ
# ផែនការសកម្មភាពអាស៊ាន
# ស្តីពី
# វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
# ឆ្នាំ ២០១៦-២០២៥

## ASEAN Plan of Action on Science, Technology and Innovation ( APASTI ) 2016-2025

**ក្រសួងឧស្សាហកម្ម និងសិប្បកម្ម**
**គណៈកម្មាធិការជាតិសម្រាប់កិច្ចសហប្រតិបត្តិការអាស៊ាន ផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា**
**( ឆ្នាំ ២០១៦ )**

## ផែនការសកម្មភាពអាស៊ានស្តីពី
## វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ២០១៦-២០២៥ (APASTI 2016-2025)

### I. សេចក្តីផ្តើម

**១**. ដោយទទួលស្គាល់ពីតម្រូវការបន្ទាន់របស់ប្រទេសចំនួន៥ មានឥណ្ឌូនេស៊ី ម៉ាឡេស៊ី ហ្វីលីពីន សិង្ហបុរី និងថៃ ក្នុងការខិតខំប្រឹងប្រែងរួមគ្នាជម្រុញការអភិវឌ្ឍសេដ្ឋកិច្ច វឌ្ឍនភាពនៃការអភិវឌ្ឍសង្គម និងវប្បធម៌តំបន់ សេចក្តីប្រកាសទីក្រុងបាងកក (Bangkok Declaration) ថ្ងៃទី៨ ខែសីហា ឆ្នាំ១៩៦៧ បានលើកឡើងពីមូលដ្ឋាននៃការបង្កើតសហគមន៍សហប្រជាជាតិអាស៊ីអគ្នេយ៍ ហៅកាត់ថាអាស៊ាន (ASEAN) ។ ដោយមើលឃើញភាពចាំបាច់ នៃវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ថាជាឧបករណ៍មិនអាចខ្វះបានសម្រាប់ការអភិវឌ្ឍនេះ គណៈកម្មការពិសេសមួយផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា (Ad hoc Committee on Science and Technology) ត្រូវបានបង្កើតឡើង ហើយកិច្ចប្រជុំលើកទី១ត្រូវបានរៀបចំឡើងនៅថ្ងៃទី២៧-២៩ ខែមេសា ឆ្នាំ១៩៧០ នៅទីក្រុងហ្សាកាតា ប្រទេសឥណ្ឌូនេស៊ី ដោយបានពិភាក្សាថាតើត្រូវជម្រុញ និងលើកកម្ពស់កិច្ចសហប្រតិបត្តិការវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាយ៉ាងដូចម្តេច ។ កិច្ចប្រជុំខាងលើបានឯកភាពថា កិច្ចសហប្រតិបត្តិការវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាមានគោលដៅដូចខាងក្រោម៖

(i) ផ្តួចផ្តើម និងជម្រុញកិច្ចសហប្រតិបត្តិការនៅក្នុងសកម្មភាពវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាក្នុងតំបន់

(ii) បង្កើត និងធ្វើឱ្យប្រសើរឡើងនូវការអភិវឌ្ឍធនធានមនុស្ស និងជំនាញការវិទ្យាសាស្ត្រ និងបច្ចេកវិទ្យានៅក្នុងតំបន់អាស៊ាន

(iii) សម្របសម្រួល និងពន្លឿនការផ្ទេរការបច្ចេកវិទ្យា និងការអភិវឌ្ឍវិទ្យាសាស្ត្រ ក្នុងចំណោមប្រទេសអាស៊ាន និងពីបណ្តាប្រទេសឧស្សាហកម្មជឿនលឿន ទៅក្នុងតំបន់អាស៊ាន

(iv) ធ្វើការគាំទ្រ និងជួយដល់ការដាក់អនុវត្តលទ្ធផលនៃការស្រាវជ្រាវ និងអភិវឌ្ឍ និងការប្រើប្រាស់ប្រកបដោយប្រសិទ្ធិភាពធនធានធម្មជាតិនៅក្នុងតំបន់អាស៊ាន

(v) និងផ្តល់នូវការគាំទ្រដល់ការអនុវត្តកម្មវិធីអាស៊ានបច្ចុប្បន្ន និងអនាគត ។

**២**.នៅឆ្នាំ១៩៧១ គណៈកម្មការពិសេសផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាត្រូវបានតម្លើងឱ្យក្លាយទៅជាគណៈកម្មាធិការអចិន្ត្រៃយ៍របស់អាស៊ានផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា (ASEAN Permanent Committee on Science and Technology-PCOST) ដើម្បីជានានូវការបន្តធ្វើឱ្យប្រសើរឡើង និងពង្រឹងកិច្ចសហប្រតិបត្តិការក្នុងសកម្មភាពវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ដែលនឹងអាចរួមវិភាគទានក្នុងការបង្ហាញ និងដោះស្រាយនូវបញ្ហារួមរបស់តំបន់អាស៊ាន ក៏ដូចជាជម្រុញឧត្តមភាពផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យារបស់បណ្តាប្រទេសជាសមាជិក ។ នៅពេលនោះ គណៈកម្មាធិការអចិន្ត្រៃយ៍របស់អាស៊ានផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ជាគណៈកម្មាធិការមួយ ក្នុងចំណោមគណៈកម្មាធិការចំនួន១១ ដែលបង្កើតឡើងដោយអាស៊ាន (ដូចជាផ្នែកចំណីអាហារ និងកសិកម្ម ការនាំចេញ (Shipping) ការដឹកជញ្ជូនស៊ីវិលតាមផ្លូវអាកាស ហិរញ្ញវត្ថុ ពាណិជ្ជកម្ម និងឧស្សាហកម្ម ដឹកជញ្ជូន ទេសចរ វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា សកម្មភាពវប្បធម៌-សង្គម និងប្រព័ន្ធផ្សព្វផ្សាយ) ។ ក្នុងចំណោមវិស័យទាំងនេះ មានរួមបញ្ចូលនូវផ្នែក **ចំណីអាហារដែលមានប្រូតេអ៊ីនខ្ពស់ និងមានតម្លៃថោកសម្រាប់កុមារ និងមាតា ការចងក្រងសៀវភៅផែនទីអាកាសធាតុ និងស្ថិតិអាកាសធាតុនៅអាស៊ាន ការគ្រប់គ្រងបរិស្ថាន ការគ្រប់គ្រង និងប្រើប្រាស់សារជាតុសំណល់ម្ហូបអាហារ** ។

នៅឆ្នាំ១៩៧៧ ក៏បានលើកឡើងពីគំនិតនៃការបង្កើតផែនការសកម្មភាពនេះ គឺធ្វើជាគ្រោងការមេគ្គុទេសសម្រាប់កិច្ចសហប្រតិបត្តិការវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ។

**៣.** បន្តតាមកិច្ចប្រតិបត្តិរបស់អាស៊ាន នៅឆ្នាំ១៩៧៨ គណៈកម្មាធិការអចិន្ត្រៃយ៍របស់អាស៊ានផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ត្រូវបានប្តូរឈ្មោះឱ្យទៅជា**គណៈកម្មាធិការអាស៊ានផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា** (ASEAN Committee on Science and Technology-COST) ។ គណៈកម្មាធិការអាស៊ានផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា (COST) បានបើកកិច្ចប្រជុំលើកទី១ របស់ខ្លួន នៅខែមិថុនា ឆ្នាំ១៩៧៨ ដោយនៅក្នុងនោះ COST បានសម្រេចនូវសកម្មភាពចំបង និងចាំបាច់ដំបូងបំផុត ដែលជា 1st Major Milestone របស់គេ គឺការកសាងផែនការសកម្មភាពវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាអាស៊ាន (ASEAN Plan of Action on Science and Technology-APAST) ។ **ផែនការសកម្មភាពវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាអាស៊ានលើកទី១** (1st APAST) ត្រូវបានរៀបចំរួចរាល់នៅឆ្នាំ១៩៨១ និងសម្រេចដោយគណៈកម្មាធិការអាស៊ានផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា នៅឆ្នាំ១៩៨៥ តាមរយៈកិច្ចប្រឹងប្រែងរួមគ្នារបស់ក្រុមជំនាញការដែលបង្កើតឡើងដោយ COST និងលេខាធិការដ្ឋានអាស៊ាន ។

តាមរយៈវឌ្ឍនភាពនៃកិច្ចសហប្រតិបត្តិការវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាអាស៊ានជាបន្តបន្ទាប់ រួមទាំងការចូលជាសមាជិកអាស៊ានរបស់ប្រទេសប្រ៊ុយណេនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៨៤ និងការតម្រង់ទិសថ្មីដោយកិច្ចប្រជុំកំពូលលើកទី៣ របស់អាស៊ាន នៅទីក្រុងម៉ានីលប្រទេសហ្វីលីពីននៅឆ្នាំ១៩៨៧ **ផែនការសកម្មភាពវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាអាស៊ានលើកទី១** ត្រូវបានធ្វើបច្ចុប្បន្នភាព និងបានសម្រេចដោយកិច្ចប្រជុំលើកទី៤ របស់រដ្ឋមន្ត្រីវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាអាស៊ាន (ASEAN Ministers on Science and Technology-AMST-4) នៅទីក្រុងម៉ានីល ប្រទេសហ្វីលីពីនថ្ងៃទី៣០-៣១ មករា ឆ្នាំ១៩៨៩ ។ រដ្ឋមន្ត្រីវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាអាស៊ានក៏បានបង្កើតផងដែរនូវ**មូលនិធិវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាអាស៊ាន** (ASEAN Trust Fund for Science and Technology) ដើម្បីលើកកម្ពស់កិច្ចសហប្រតិបត្តិការវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាក្នុងតំបន់ ។ មូលនិធិ ASEAN Trust Fund ក្រោយមកបានក្លាយជាមូលនិធិវិទ្យាសាស្ត្រអាស៊ាន (ASEAN Science Fund-ASF) ដោយចាប់ផ្តើមពីការរួមវិភាគទាន ៥០,០០០ ដុល្លា ពីបណ្តាប្រទេសសមាជិកអាស៊ាន និងពីរដ្ឋាភិបាល New Zealand ប្រមាណ ៥៨,២០០ ដុល្លាអាមេរិក ។

នៅក្នុងកិច្ចប្រជុំកំពូលលើកទី១២ ថ្ងៃទី១៣ ខែមករា ឆ្នាំ២០០៧ នៅទីក្រុងសេប៊ុយ ប្រទេសហ្វីលីពីន ថ្នាក់ដឹកនាំអាស៊ានបានឯកភាពគ្នាជម្រុញការបង្កើតសហគមន៍អាស៊ាន ចាប់ពី២០០៩-២០១៥ ។ អនុលោមតាមសេចក្តីសម្រេចនេះ រដ្ឋមន្ត្រីពាក់ព័ន្ធបានចាប់ផ្តើមសម្របសម្រួលក្នុងការបង្កើត Blueprint សម្រាប់ APSC, AEC and ASCC ។ AEC Blueprint ត្រូវបានបញ្ចប់នៅឆ្នាំ២០០៧ រីឯ Blueprint សម្រាប់ APSC and ASCC និងផែនការការងារលើកទី២ នៃកិច្ចផ្តួចផ្តើមសមាហរណកម្មអាស៊ាន (Initiative for ASEAN Integration-IAI) ត្រូវបានសម្រេច និងទទួលយកក្នុងកិច្ចប្រជុំកំពូលលើកទី១៥ របស់អាស៊ាន ថ្ងៃទី០១ ខែមីនា ឆ្នាំ២០០៩ នៅ Cha Am, Hua Hin ប្រទេសថៃ ។

ឆ្ពោះទៅរកការបង្កើតសហគមន៍អាស៊ាន អន្តរគមន៍ផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាត្រូវបានដាក់ឱ្យដំណើរការនៅក្រោមបរិបថការអភិវឌ្ឍធនធានមនុស្សនៃ ASCC Blueprint ដោយរួមបញ្ចូលទាំងការអភិវឌ្ឍគោលនយោបាយ និងយន្តការដើម្បីគាំទ្រយ៉ាងសកម្មក្នុងកិច្ចសហប្រតិបត្តិការផ្នែកស្រាវជ្រាវ និងការអភិវឌ្ឍវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ការផ្ទេរបច្ចេកវិទ្យា និងការនាំបច្ចេកវិទ្យាទៅកាន់ទីផ្សារ និងការបង្កើតបណ្តាញទំនាក់ទំនងយ៉ាងរឹងមាំរវាងស្ថាប័ន ដោយមានការចូលរួមយ៉ាងសកម្មរបស់វិស័យឯកជន និងស្ថាប័នពាក់ព័ន្ធផ្សេងទៀត ។

ឆ្លើយតបទៅនឹងគោលដៅទាំងនេះ សកម្មភាពមួយចំនួនត្រូវបានដាក់ចេញ មានដូចខាងក្រោម៖

(i) ត្រឹមឆ្នាំ២០១១ ត្រូវបង្កើតឱ្យបាននូវបណ្ដាញទំនាក់ទំនងរវាងមជ្ឈមណ្ឌលឧត្តមភាពផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ដើម្បីលើកកម្ពស់កិច្ចសហប្រតិបត្តិការ ផ្លាស់ប្ដូរឧបករណ៍ស្រាវជ្រាវ ការផ្ទេរបច្ចេកវិទ្យា និងការនាំបច្ចេកវិទ្យាទៅកាន់ទីផ្សារ ការអភិវឌ្ឍវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា រួមគ្នា

(ii) ពង្រឹងការសិក្សាស្រាវជ្រាវ និងអភិវឌ្ឍន៍រួមគ្នា នៅក្នុងការដាក់អនុវត្តវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ដើម្បីលើកកម្ពស់សុខុមាលភាពសហគមន៍

(iii) សម្របសម្រួលឱ្យមានការផ្លាស់ប្ដូរ និងចល័តអ្នកវិទ្យាសាស្ត្រ និងអ្នកស្រាវជ្រាវ របស់ស្ថាប័នវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាសាធារណៈ និងឯកជន

(iv) បង្កើតការចងសម្ព័ន្ធមេត្រីភាពជាយុទ្ធសាស្ត្រជាមួយវិស័យឯកជន ដើម្បីលើកកម្ពស់កិច្ចសហប្រតិបត្តិការស្រាវជ្រាវ និងអភិវឌ្ឍន៍ ការផ្ទេរបច្ចេកវិទ្យា និងធ្វើពាណិជ្ជកម្មបច្ចេកវិទ្យា

(v) បង្កើតអាហារូបករណ៍អាស៊ាន និងកាលានុវត្តន៍ភាពទទួលបានអាហារូបករណ៍ ដើម្បីគាំទ្រដល់វិទ្យាស្ថាន ASEAN Virtual Institute of Science and Technology (AVIST) និងសកម្មភាពវិទ្យាសាស្ត្រពាក់ព័ន្ធផ្សេងទៀត

(vi) បញ្ជ្រាបការយល់ដឹងឱ្យបានទូលំទូលាយ នូវការដាក់អនុវត្តវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព

(vii) ពង្រីក និងធ្វើឱ្យមាននិរន្តរភាពនូវការប្រើប្រាស់ប្រព័ន្ធទំនាក់ទំនងវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាអាស៊ាន (ASEAN Science and Technology Network-ASTNET) និងប្រព័ន្ធទំនាក់ទំនងវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាផ្សេងទៀត

(viii) លើកកម្ពស់ការអភិវឌ្ឍ ការប្រើប្រាស់ និងការចែករំលែកទិន្នន័យចល័ត (Digital Content) ក្នុងចំណោមប្រទេសសមាជិកអាស៊ាន ។

ទាំងនេះ គេអាចកត់សំគាល់បានថា គោលបំណងជាយុទ្ធសាស្ត្រ (Strategic Thrusts) និងសកម្មភាពពាក់ព័ន្ធនឹងផែនការសកម្មភាពអាស៊ានផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាដែលបានអភិវឌ្ឍជាបន្តបន្ទាប់ ដើម្បីបង្ហាញពីទស្សនវិស័យជាយុទ្ធសាស្ត្រ ដែលជាមូលដ្ឋានគឺចង់សម្រេចឱ្យបានសេចក្ដីប្រាថ្នារួម ។ ទាំងនេះគឺរួមបញ្ចូលទាំងការពង្រឹងឱ្យកាន់តែខ្លាំងនូវកិច្ចសហប្រតិបត្តិការជាមួយស្ថាប័ន និងភាគីពាក់ព័ន្ធ លើផ្នែកកសាងសមត្ថភាពការស្រាវជ្រាវ និងអភិវឌ្ឍន៍ (R&D) ការបាចសាចបច្ចេកវិទ្យា (Technology Diffusion) និងការធ្វើពាណិជ្ជកម្មបច្ចេកវិទ្យា ការពង្រឹងហេដ្ឋារចនាសម្ព័ន្ធវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ប្រព័ន្ធគាំទ្រ និងគ្រប់គ្រង បង្ហាញឡើងពីអត្ថប្រយោជន៍ ដែលកើតចេញពីការអភិវឌ្ឍ និងការប្រើប្រាស់ផលិតផល និងសេវាកម្មវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា និងពង្រឹងកិច្ចសហប្រតិបត្តិការជាមួយវិស័យឯកជន ដៃគូចរចារ និងដៃគូផ្សេងទៀត ។

តារាងទី១ ការប្រៀបធៀបគោលបំណងជាយុទ្ធសាស្ត្រ (Strategic Thrusts) និងសកម្មភាព របស់ផែនការសកម្មភាពអាស៊ានផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា

| | APAST 1996-2000 | APAST 2001-2004 (បន្តរហូតដល់២០០៦) | APAST 2007-2011 (បន្តរហូតដល់២០១៥) |
|---|---|---|---|
| ចក្ខុវិស័យ (Vision) | អាស៊ានដែលមានការប្រកួតប្រជែងបច្ចេកវិទ្យា មានសមត្ថកិច្ច និងសមត្ថភាពបច្ចេកវិទ្យា មានធនធានមនុស្សដែលទទួលបានការបណ្តុះបណ្តាល និងសមត្ថភាពពេញលេញផ្នែកបច្ចេកវិទ្យា និងប្រព័ន្ធទំនាក់ទំនងរឹងមាំរបស់ស្ថាប័នវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា និងមជ្ឈមណ្ឌលឧត្តមភាព | | |
| គោលដៅ/គោលបំណង (Goals/Objectives) | ១.ពង្រឹងឱ្យបានខ្លាំងនូវកិច្ចសហប្រតិបត្តិការផ្ទៃក្នុងរបស់អាស៊ាន ផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ដោយមានការចូលរួមយ៉ាងសកម្មរបស់វិស័យឯកជនដែលមានសមត្ថភាព និងអាចរស់រានដោយខ្លួនឯង<br>២.បង្កើតបណ្តាញទំនាក់ទំនងនៃហេដ្ឋារចនាសម្ព័ន្ធ និងកម្មវិធីវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា សម្រាប់ការអភិវឌ្ឍធនធានមនុស្សទាំងវិស័យសាធារណៈ និងឯកជន<br>៣.ធ្វើឱ្យសកម្ម និងប្រសើរឡើង ប្រកបដោយអត្ថប្រយោជន៍សេដ្ឋកិច្ច នូវការផ្ទេរបច្ចេកវិទ្យារវាងស្ថាប័នស្រាវជ្រាវ និងឧស្សាហកម្ម<br>៤.ពង្រីកការបញ្ជ្រាបការយល់ដឹងទៅដល់វិស័យសាធារណៈ អំពីសារៈសំខាន់នៃវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ដើម្បី ការអភិវឌ្ឍសេដ្ឋកិច្ចអាស៊ាន<br>៥.ពង្រីកកិច្ចសហប្រតិបត្តិការវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាជាមួយសហគមន៍អន្តរជាតិ | ១.ពង្រឹងឱ្យបានខ្លាំងនូវកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ការស្រាវជ្រាវ និង អភិវឌ្ឍ (R&D) រវាងវិស័យសាធារណៈ និងឯកជនដែលមានជំហររឹងមាំឆ្ពោះទៅមុខ មានការអប់រំខ្ពស់ផ្នែកក្នុង<br>២.វិសាលភាពការងារទូលំទូលាយនៃកម្មវិធីក្នុងតំបន់ និងគាស់កកាយបទពិសោធន៍ និងធនធាន និងការផ្តួចផ្តើមសកម្មភាពអាស៊ានជួយអាស៊ាន (ASEAN-Help-ASEAN) ដែលនឹងជួយដល់សមាជិកអាស៊ានថ្មី ឆ្ពោះទៅមុខទៅតាមក្រាភិកការសិក្សារៀនសូត្រ និងក្លាយជាប្រទេសមានការប្រកួតប្រជែងសេដ្ឋកិច្ច<br>៣.សហគមន៍វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ដែលមានភាពបត់បែនបាន មានទេពកោសល្យ និងគំនិតបង្កើតថ្មី ដែលជំជាត់ទៅដោយការបង្កើតចំណេះ ដឹង និងការយកចំណេះដឹងទាំងនេះទៅអនុវត្ត<br>៤.ប្រព័ន្ធលើកទឹកចិត្ត និងលើកសរសើរ ដើម្បីលើកកម្ពស់នវានុវត្តន៍ និងការធ្វើពាណិជ្ជកម្មបច្ចេកវិទ្យា (Technology commercialization) និងទាក់ទាញអ្នកមានទេពកោសល្យ ទៅកាន់ការ | ១.ជម្រុញវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាធ្វើជាវិស័យដ៏មានសារៈសំខាន់នៅក្នុងជីវភាពនៃការអភិវឌ្ឍសេដ្ឋកិច្ច ពង្រឹងសុខុមាលភាពសហគមន៍ និងធ្វើឱ្យប្រសើរឡើងនូវការចូលសហគមន៍អាស៊ាន តាមរយៈការអភិវឌ្ឍធនធានមនុស្ស ការស្រាវជ្រាវ និងអភិវឌ្ឍ និងការផ្តល់សេវាកម្មបច្ចេកទេស ដើម្បីឆ្លើយតបទៅនឹងតម្រូវការនៃការធ្វើសមាហរណកម្មសេដ្ឋកិច្ច<br>២.ដាក់ឱ្យអនុវត្តឧបករណ៍វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា និងវិធីសាស្ត្រធ្វើផែនការសេដ្ឋកិច្ច និងឧស្សាហកម្ម<br>៣.រៀបចំវិធីសាស្ត្រគ្រប់ជ្រុងជ្រោយជាលក្ខណៈប្រព័ន្ធ ក្នុងការអនុវត្តកម្មវិធីអាស៊ាន-ជួយអាស៊ាន ដើម្បីបង្ហាញពីតម្រូវការវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា និងពង្រឹងហេដ្ឋារចនាសម្ព័ន្ធវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា របស់ប្រទេសសមាជិកអាស៊ានដែលមានការអភិវឌ្ឍតិចតួច<br>៤.ប្រើប្រាស់វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ជា |

| | | | |
|---|---|---|---|
| | | អនុវត្តវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា<br>៥.ការបណ្តុះឡើង និងការបន្តនិរន្តរភាពកម្មវិធីវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា តាមរយៈវិធីនវានុវត្តន៍នៃការអង្កេតទៅលើសេចក្តីព្យាយាមផ្នែកវិទ្យាសាស្ត្រ និងការបង្កើតចំណូល<br>៦.ប្រព័ន្ធគ្រប់គ្រងដ៏ទូលំទូលាយមួយ សម្រាប់អនាគតសហគ្រាសដែលមានការច្នៃប្រឌិតបង្កើតថ្មីច្បាស់លាស់ និងមានភាពជាសហគ្រិន | ឧបករណ៍ចំបងសម្រាប់អាស៊ានក្នុងការជម្រុញទៅមុខរួមគ្នា និងជាធ្លុងមួយ<br>៥.កសាងដោយឈរលើមូលដ្ឋានផែនការសកម្មភាពអាស៊ានផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា (APAST) ២០០១-២០០៤ ដែលបន្តរហូតដល់ឆ្នាំ២០០៦ ។ |
| **យុទ្ធសាស្ត្រ និងផែនការសកម្មភាព** | **យុទ្ធសាស្ត្រទី១៖** គាំទ្រដល់កម្មវិធីថ្នាក់តំបន់ ផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ដែលផ្តល់អត្ថប្រយោជន៍សេដ្ឋកិច្ច និងសង្គមដល់ប្រទេសសមាជិកអាស៊ាន<br><br>**សកម្មភាព៖**<br>១.ចង្អុលបង្ហាញអំពីវិស័យឯកជន និងអ្នកប្រើប្រាស់ចុងក្រោយនូវលទ្ធផលការស្រាវជ្រាវ និង**ស្វែងរក**ការចូលរួមយ៉ាងសកម្មរបស់វិស័យឯកជនក្នុងការស្រាវជ្រាវ និងអភិវឌ្ឍ<br>២.គាំទ្រដល់ការលើកកម្ពស់ស្តង់ដារ ការធ្វើតេស្ត និងសកម្មភាពធានាគុណភាព របស់វិស័យឯកជន<br>៣.ជ្រើសរើស និងបង្កើតអាទិភាពនៃគម្រោងតាមវិស័យ កម្មវិធី ដែលមានឥទ្ធិពលខ្លាំង និងមានអត្ថប្រយោជន៍ខ្ពស់បំផុតដល់អាស៊ាន និងជាសកល<br>៤.បង្កើតសេរីនៃលក្ខណៈវិនិច្ឆ័យសម្រាប់វិស័យ | Thrust 1: ភ្ជាប់បណ្តាញទំនាក់ទំនងរវាងមជ្ឈមណ្ឌលឧត្តមភាព និងកម្មវិធីវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ដើម្បីប្រសិទ្ធិភាពធនធាន និងសម្រេចឱ្យបានលទ្ធផលជាអតិបរិមា<br>**សកម្មភាព**<br>១.បង្កើតឱ្យបានឆាប់នូវបណ្តាញទំនាក់ទំនងវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាអាស៊ាន (ASTNET) និងបង្កើតឱ្យមានជាចំណុចទាក់ទងសម្រាប់សកម្មភាពដើម្បីធ្វើឱ្យប្រសើរឡើង និងមានចីរភាពនៃបណ្តាញទាក់ទងនេះ<br>២.កំណត់មជ្ឈមណ្ឌលឧត្តមភាពសម្រាប់វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា អភិវឌ្ឍធនធាននៃប្រព័ន្ធទិន្នន័យ និងបណ្តាញទំនាក់ទំនង ដើម្បីសម្របសម្រួល ការចែករំលែកព័ត៌មាន ការអភិវឌ្ឍធនធានមនុស្ស និងកិច្ចសហប្រតិបត្តិការបច្ចេកទេសរវាងវិស័យសាធារណៈ និងឯកជន<br>៣.បង្កើតបណ្តាញទំនាក់ទំនងនៃគម្រោង និងប្រព័ន្ធ | Thrust 1: ជម្រុញកិច្ចសហប្រតិបត្តិការវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា និងធ្វើឱ្យប្រសើរឡើងនូវការធ្វើពាណិជ្ជកម្មបច្ចេកវិទ្យា (Technology Commercialization)<br>**សកម្មភាព**<br>១.ចង្អុលបង្ហាញ និងបង្កើតគម្រោងដែលចែករំលែកតម្លៃ (Cost-shared projects) តាមរយៈអនុគណៈកម្មាធិការវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា (Sub-Committees of COST)<br>២.អភិវឌ្ឍក្របខណ្ឌគោលនយោបាយសម្រាប់ដៃគូជាយុទ្ធសាស្ត្រ នៅក្នុងការស្រាវជ្រាវ និងអភិវឌ្ឍ (R&D) និងការអភិវឌ្ឍបច្ចេកវិទ្យាជាមួយវិស័យឯកជន<br>៣.ចង្អុលបង្ហាញ និងស្វែងរកក្រុមហ៊ុន ឬអង្គភាព Spin-offs ពាណិជ្ជកម្មដ៏សមរម្យដើម្បីធ្វើធុរកិច្ចជាមួយវិស័យឯកជន |

| | | | |
|---|---|---|---|
| | គម្រោង និងកម្មវិធីជាអាទិភាព ដោយផ្អែកលើកត្តាបច្ចេកទេស និងសេដ្ឋកិច្ច<br>៥.កំណត់មជ្ឈមណ្ឌលឧត្តមភាពសម្រាប់ការអភិវឌ្ឍវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា | ទិន្នន័យថ្នាក់ជាតិ និងថ្នាក់តំបន់ ដើម្បីគាំទ្រដល់ការធ្វើសមាហរណកម្ម និងសម្រេចឱ្យបានប្រសិទ្ធិភាពខ្ពស់នូវការអនុវត្តថ្នាក់តំបន់ ដោយធ្វើពិពិធកម្មសេដ្ឋកិច្ច ដំណាក់ការនៃការអភិវឌ្ឍ និងភាពត្រៀមខ្លួនជាស្រេចរបស់ប្រទេសសមាជិកអាស៊ាន<br>៤.លើកកម្ពស់វិស័យសហគ្រាសធុនតូច និងមធ្យមដែលទំនើប និងមានការប្រកួតប្រជែង នៅក្នុងអាស៊ានតាមរយៈ ASTNET និងបណ្តាញទំនាក់ទំនង និងធនធានវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាដែលពាក់ព័ន្ធផ្សេងទៀត ។ | ៤.ធ្វើការផ្ទេរ និងដាក់អនុវត្តចំណេះធ្វើសម្រាប់សុខុមាលភាពសហគមន៍ |
| | **យុទ្ធសាស្ត្រទី២៖ ផ្តល់ការសម្របសម្រួល និងការគ្រប់គ្រងឱ្យបានល្អនូវសកម្មភាពវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា**<br><br>**<u>សកម្មភាព៖</u>**<br>១.បង្កើតប្រព័ន្ធរៀបចំផែនការធ្វើគម្រោង និងកម្មវិធី និងតាមដាន និងត្រួតពិនត្យ<br>២.ដាក់ចេញនូវក្រុមគោលដៅសំខាន់ៗដើម្បីដឹកនាំការអនុវត្តផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាថ្នាក់តំបន់<br>៣.រៀបចំសេចក្តីណែនាំអំពីការទទួលបាន និងគ្រប់គ្រងមូលនិធិរបស់កម្មវិធី និងគម្រោង<br>៤.ធ្វើឱ្យប្រសើរឡើងនូវចំណងភ្ជាប់ជាយុទ្ធសាស្ត្រជាមួយឧស្សាហកម្ម (ភាគីពាក់ព័ន្ធទាំងអស់)<br>៥.រៀបចំសេចក្តីណែនាំអំពីការដាក់ទៅកាន់ទីផ្សារ នូវ | **Thrust 2: អភិវឌ្ឍគោលនយោបាយសម្រាប់ជ្រើសរើសកម្មវិធី ការរចនា និងការគ្រប់គ្រង នៅក្នុងសហគ្រាស S&Tថ្មី ដោយគិតទៅលើតម្រូវការតាមវិស័យ និងតម្រូវការរបស់ប្រទេសជាសមាជិកថ្មី**<br>**<u>សកម្មភាព៖</u>**<br>១.បង្កើតគោលនយោបាយដឹកនាំការជ្រើសរើសកម្មវិធី គម្រោង ការផ្តល់ និងគ្រប់គ្រងមូលនិធិ<br>២.បង្កើតគោលនយោបាយ និងគ្រោងការសម្រាប់កិច្ចសហប្រតិបត្តិការជាមួយវិស័យឯកជន លើការស្រាវជ្រាវ និងអភិវឌ្ឍ (R&D) និងការអភិវឌ្ឍបច្ចេកវិទ្យា<br>៣.បង្កើតគោលនយោបាយ និងយន្តការសម្រាប់ការចែករំលែកតម្លៃ និងផលប្រយោជន៍និងការចូលរួមស្មើភាពគ្នា ផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា នៅក្នុងក្រុមហ៊ុនបង្កើតថ្មី Spin-off Companies | **Thrust 2: អភិវឌ្ឍធនធានមនុស្សផ្នែក វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា**<br><br>**<u>សកម្មភាព៖</u>**<br>១.ជម្រុញការផ្សព្វផ្សាយកម្មវិធីអាស៊ានជួយអាស៊ាន ដោយផ្តោតទៅលើការអភិវឌ្ឍធនធានមនុស្ស និងការកសាងសមត្ថភាព<br>២.រៀបចំ និងអនុវត្តកម្មវិធីបណ្តុះបណ្តាល ដើម្បីឆ្លើយតបទៅនឹងតម្រូវការឧស្សាហកម្មដែលមានតម្លៃបន្ថែមខ្ពស់ ដែលជួយជម្រុញការប្រកួតប្រជែងជាសកលរបស់អាស៊ាន<br>៣.រៀបចំកម្មវិធីបណ្តុះបណ្តាល និងនៅពេលចាំបាច់ ប្រើប្រាស់ជំនួយរបស់វិទ្យាស្ថាន ASEAN Virtual Institute of Science and Technology |

| | | | |
|---|---|---|---|
| | លទ្ធផលនៃការសិក្សាស្រាវជ្រាវ និងអភិវឌ្ឍន៍ វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា រួមទាំងការចែករំលែក ព័ត៌មានអំពីកម្មសិទ្ធបញ្ញា និងការបង់តម្លៃសិទ្ធ | ៤.រៀបចំក្របខណ្ឌការងារសម្រាប់ការពារកម្មសិទ្ធបញ្ញា និងការផ្ទេរបច្ចេកវិទ្យានៅក្នុងអាស៊ាន<br>៥.រៀបចំយន្តការសម្រាប់លើកគម្រោង និងអនុវត្តគម្រោងអាស៊ានជួយអាស៊ាន ( ASEAN-help-ASEAN projects )<br>៦.បង្កើតវេទិកាអាស៊ានស្គាល់អាស៊ាន ( ASEAN-know-ASEAN platform ) ដើម្បីជំរុញឱ្យបានជិតគ្នានូវចំណុចប្រសព្វរវាងអ្នកឯកទេសវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា និងអ្នកសម្រេចចិត្តផ្នែកគោលនយោបាយនៅក្នុងវិស័យសាធារណៈ និងឯកជន<br>៧.រៀបចំយន្តការជម្រុញបញ្ជ្រាបការយល់ដឹងជាសាធារណៈ អំពីលទ្ធផលសម្រេចបានពីកិច្ចសហប្រតិបត្តិការផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា | ( AVIST )<br>៤.បង្កើតឱ្យមានជាអាហារូបករណ៍អាស៊ាន និងកម្មវិធីផ្តល់អាហារូបករណ៍ ដើម្បីជួយគាំទ្រដល់កម្មវិធី e-ASEAN និងកិច្ចដំណើរការហេដ្ឋារចនាសម្ព័ន្ធព័ត៌មានអាស៊ាន ( ASEAN Information Infrastructure ) |
| | **យុទ្ធសាស្ត្រទី៣៖ អភិវឌ្ឍធនធានមនុស្សផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា**<br><br>***<u>សកម្មភាព៖</u>***<br>១.អភិវឌ្ឍធនធានមនុស្សផ្នែកស្រាវជ្រាវ និងអភិវឌ្ឍន៍ (R&D)ដើម្បីឆ្លើយតបទៅនឹងតម្រូវការតាមវិស័យ<br>២.បង្កើតកម្មវិធីផ្តល់អាហារូបករណ៍វិទ្យាសាស្ត្រ និងបច្ចេកវិទ្យាអាស៊ាន ( ASEAN S&T Fellowship Programme ) | Thrust 3: **ពង្រឹងកិច្ចសហប្រតិបត្តិការស្រាវជ្រាវ និងអភិវឌ្ឍន៍នៅផ្នែកបច្ចេកវិទ្យាជាយុទ្ធសាស្ត្រ និងបច្ចេកវិទ្យា មានចរិតរកឃើញថ្មី និងការនាំបច្ចេកវិទ្យាទៅកាន់ទីផ្សារ** ( Technology Commercialization )<br>***<u>សកម្មភាព៖</u>***<br>១.ជួលក្រុមដឹកនាំគម្រោង ( PSG ) សម្រាប់កម្មវិធីតាមផ្នែកនីមួយៗ ដើម្បីកៀងគរដៃគូចរចារ និងវិស័យឯកជនចូលរួមជាមួយ<br>២.ប្រកាន់យកវិធានបណ្តុះបណ្តាលនិងគ្រប់ជ្រុងជ្រោយ ដើម្បីកំណត់វិស័យអាទិភាព សម្រាប់កិច្ចសហ - ប្រតិបត្តិការស្រាវជ្រាវតាមរយៈដំណើរការវិភាគ | Thrust 3: **ភ្ជាប់បណ្តាញទំនាក់ទំនងមជ្ឈមណ្ឌលឧត្តមភាពវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា និងកម្មវិធីការងារវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា**<br><br>***<u>សកម្មភាព៖</u>***<br>១.បង្កើតបណ្តាញទំនាក់ទំនងបច្ចេកវិទ្យាសម្រាប់អ្នកអនុវត្ត និងស្វែងយល់របស់អាស៊ាន និងលំហាត់ស្វែងយល់បច្ចេកវិទ្យាសម្រាប់វិស័យដែលបានកំណត់<br>២.អភិវឌ្ឍប្រព័ន្ធទិន្នន័យធនធាន និងបណ្តាញទំនាក់ទំនងវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ដើម្បី |

| | | | |
|---|---|---|---|
| | | និងធ្វើសន្និដ្ឋានបច្ចេកវិទ្យា (ការយល់ដឹងជាមុន)<br>៣.ពង្រឹងកិច្ចសហប្រតិបត្តិការស្រាវជ្រាវក្នុងអាស៊ាន (Intra-ASEAN Research Collaboration) ដើម្បីអភិវឌ្ឍសមត្ថភាព និងបច្ចេកវិទ្យារកឃើញថ្មី<br>៤.ចង្អុលបង្ហាញ និងស្វែងរក Commercial Spin-offs តាមរយៈភាពជាដៃគូជាមួយវិស័យឯកជន<br>៥.រួមវិភាគទានក្នុងហេដ្ឋារចនាសម្ព័ន្ធ និងគម្រោង e-ASEAN តាមរយៈការធ្វើខ្លួនឱ្យសកម្ម និងធ្វើខ្លួនជាអ្នកប្រើប្រាស់ចុងក្រោយ និងអ្នកអភិវឌ្ឍមាតិកាក្នុងពេលកំពុងគាស់កកាយធនធានរបស់ក្រុមទំនុកបម្រុងថវិកា និងទំនាក់ទំនង របស់គណៈកម្មាធិការវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា | សម្របសម្រួលការចែករំលែកព័ត៌មាន និងកិច្ចសហប្រតិបត្តិការបច្ចេកទេសរវាងស្ថាប័ន ក្នុងវិស័យសាធារណៈ និងឯកជន<br>៣.ជម្រុញ និងបន្តនិរន្តរភាពនៃការប្រើប្រាស់បណ្តាញទំនាក់ទំនងបច្ចេកវិទ្យាអាស៊ាន (ASEAN Science and Technology Network-ASTNET) និងប្រព័ន្ធទំនាក់ទំនងវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាផ្សេងទៀត |
| | **យុទ្ធសាស្ត្រទី៤៖ ភ្ជាប់បណ្តាញទំនាក់ទំនងព័ត៌មានរបស់មជ្ឈមណ្ឌលឧត្តមភាព**<br><br>**<u>សកម្មភាព៖</u>**<br>១.អភិវឌ្ឍបណ្តាញទំនាក់ទំនងព័ត៌មានបច្ចេកវិទ្យាអាស៊ាន<br>២.អភិវឌ្ឍប្រព័ន្ធទិន្នន័យបច្ចេកវិទ្យារបស់ក្រុមធុរៈកិច្ចអាស៊ាន<br>៣.អភិវឌ្ឍប្រព័ន្ធទិន្នន័យជំនាញការវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាអាស៊ាន និងឧបករណ៍ បរិក្ខាវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា | **Thrust 4: អភិវឌ្ឍធនធានមនុស្សដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់ e-ASEAN ប្រទេសសមាជិកអាស៊ានថ្មី និងតម្រូវការសេដ្ឋកិច្ចផ្អែកលើចំណេះដឹង (Knowledge Economy)**<br><br>**<u>សកម្មភាព៖</u>**<br>១.ធ្វើការចល័តធនធាន និងបណ្តាញទំនាក់ទំនងវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាដើម្បីបង្កើតបរិយាកាសសិក្សាពីជីវភាពរស់នៅ និងនវានុវត្តន៍ និងដើម្បីគាំទ្រដល់ការបណ្តុះបណ្តាលសហគ្រិនវ័យក្មេង<br>២.រៀបចំកម្មវិធីអភិវឌ្ឍធនធានមនុស្សដើម្បីឆ្លើយតបទៅនឹងតម្រូវការតាមវិស័យ របស់ប្រទេសសមាជិកអាស៊ានទើបចូលថ្មី ជាពិសេសការបណ្តុះបណ្តាល | **Thrust 4: ជម្រុញបញ្ញាបការយល់ដឹង និងការប្រើប្រាស់វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា**<br><br>**<u>សកម្មភាព៖</u>**<br>១.បង្កើនការយល់ដឹងអំពីគម្រោង និងលទ្ធផលសម្រេចបានផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាតាមរយៈការអនុវត្តកម្មវិធីដ៏សមរម្យ ដូចជាកម្មវិធី ASEAN Science and Technology Week-ASTW សន្និសីទចំណីអាហារអាស៊ាន (ASEAN Food Conference) ទស្សនាវដ្តីអាស៊ានស្តីពីវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាសម្រាប់ |

| | | | |
|---|---|---|---|
| | ៤.អភិវឌ្ឍយន្តការសិក្សា និងចម្លងបច្ចេកវិទ្យា | គ្រូបង្គោល និងការធ្វើបច្ចុប្បន្នភាពអ្នកជំនាញឯកទេស<br>៣.បង្កើតអាហារូបករណ៍អាស៊ាន និងកម្មវិធីផ្តល់អាហារូបករណ៍ដើម្បីគាំទ្រ e-ASEAN និងដំណើរការអនុវត្តរបស់ហេដ្ឋារចនាសម្ព័ន្ធព័ត៌មានអាស៊ាន<br>៤.បង្កើតកម្មវិធីផ្លាស់ប្តូរព័ត៌មានក្នុងអាស៊ាន សម្រាប់អ្នកសម្រេចចិត្តដ៏មានទេព្យកោសល្យរបស់អាស៊ាន ដែលស្ថិតនៅក្នុងមជ្ឈមណ្ឌលធនធានសំខាន់ៗ និងស្ថាប័នរដ្ឋឬដែលជាអ្នកចូលរួមក្នុងកម្មវិធីផ្តល់អាហារូបករណ៍សម្រាប់ផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា | ការអភិវឌ្ឍ (ASEAN Journal on Science and Technology for Development-AJSTD) និងព្រឹត្តិការណ៍គាំទ្រសកម្មភាពផ្សេងទៀតរបស់អាស៊ាន<br>២.បង្កើតចំណងទាក់ទងជាមួយអង្គភាព និងគណៈកម្មការផ្សេងទៀតរបស់អាស៊ាន សម្រាប់អនុវត្តរួមគ្នា និងការប្រើប្រាស់វិទ្យាសាស្ត្រ និងបច្ចេកវិទ្យាជាឧបករណ៍ដ៏ចំបងក្នុងការឆ្លើយតបទៅនឹងគម្រោងអាទិភាពនៅក្នុងអាស៊ាន<br>៣.ធ្វើឱ្យប្រសើរឡើងនូវការប្រកួតប្រជែងរបស់សហគ្រាសធុនតូច និងមធ្យម នៅក្នុងអាស៊ាន តាមរយៈការដាក់អនុវត្តឧបករណ៍ និងវិធីសាស្ត្រវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា<br>៤.លើកកម្ពស់ការប្រើប្រាស់សេវាកម្មដែលផ្តល់ដោយមជ្ឈមណ្ឌល ASEAN Seismological and Meteorological Center-ASMC និងមជ្ឈមណ្ឌលព័ត៌មានអាស៊ានអំពីការរំជួយដី (ASEAN Earthquake Information Center) |
| | **យុទ្ធសាស្ត្រទី៥៖ លើកកម្ពស់ការផ្ទេរបច្ចេកវិទ្យារវាងសាលា វិទ្យាស្ថាន និងឧស្សាហកម្ម** | Thrust 5: **ធ្វើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងមាតិកាវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា សម្រាប់ជួយដល់ការស្រាវជ្រាវ ការអភិវឌ្ឍធនធានមនុស្ស ការប្រមើលមើល និងព្យាករណ៍បច្ចេកវិទ្យា និងការប្រមូលផ្តុំទេព្យកោសល្យ ការនាំបច្ចេកវិទ្យាទៅកាន់ទីផ្សារ និងអភិវឌ្ឍការចូលរួមធុរកិច្ច** | Thrust 5: **ពង្រឹងហេដ្ឋារចនាសម្ព័ន្ធ និងប្រព័ន្ធគាំទ្រវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា** |

| | | | |
|---|---|---|---|
| | **សកម្មភាព៖**<br>១.បង្កើតយន្តការផ្ទេរបច្ចេកវិទ្យា<br>២.បង្កើតសេវីនៃការលើកទឹកចិត្តដើម្បីជម្រុញការនាំបច្ចេកវិទ្យាពីការស្រាវជ្រាវទៅកាន់ទីផ្សារ និងធ្វើការចល័តធនធានមនុស្សផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា | **សកម្មភាព៖**<br>១.បង្កើតបណ្តាញចងសម្ព័ន្ធ និងទំនាក់ទំនងការសិក្សា និងការស្រាវជ្រាវវិទ្យាសាស្ត្រ (S&T Research and Education Network Alliance-ASTRENA) និងបច្ចេកវិទ្យា នៅពេលជាមួយគ្នាចាប់យកសារៈប្រយោជន៍ចំណងភ្ជាប់អ៊ិនធឺណិតទម្រង់ទ្វេភាគី និងពហុភាគីនៅពេលបច្ចុប្បន្ន និងអនាគត<br>២.ធ្វើការអភិវឌ្ឍប្រព័ន្ធទិន្នន័យ ASTMIS សម្រាប់ងាយស្រួលក្នុងការគ្រប់គ្រង ធ្វើបច្ចុប្បន្នភាព និងស្វែងរកទិន្នន័យ និងអភិវឌ្ឍសូចនាករដើម្បីវាស់វែងមាតិកាបច្ចេកវិទ្យា ក្នុងផលិតផល និងសេវាកម្ម និងឥទ្ធិពលទៅលើសេដ្ឋកិច្ចជាតិ និងសេដ្ឋកិច្ចតំបន់<br>៣.បង្កើតមាតិកាសម្រាប់ហេដ្ឋារចនាសម្ព័ន្ធព័ត៌មានអាស៊ាន នៅពេលដំណើរការបណ្តាញទំនាក់ទំនង ASTNET ប្រព័ន្ធ ASTMIS និងបណ្តាញទំនាក់ទំនងផ្សេងទៀតរបស់អនុគណៈកម្មាធិការ (Sub-Committees)<br>៤.អភិវឌ្ឍបណ្តាញទំនាក់ទំនងការសិក្សាតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន (e-Learning Network) សម្រាប់ការសិក្សា និងវគ្គបណ្តុះបណ្តាលឯកទេសជាបន្តបន្ទាប់<br>៥.អភិវឌ្ឍចំណងភ្ជាប់តាមប្រព័ន្ធព័ត៌មានវិទ្យា(e-links) រវាងគណៈកម្មាធិការវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាសាលា និងសហគមន៍ធុរកិច្ច | **សកម្មភាព៖**<br>១.បំពេញបង្គ្រប់ផែនការតម្លើងថវិការបស់មូលនិធិអាស៊ាន និងវិធីសាស្ត្រផ្សេងទៀត ក្នុងការបង្កើនថវិកាមូលនិធិនេះ<br>២.អភិវឌ្ឍសេរីសូចនាករវិទ្យាសាស្ត្រនិងបច្ចេកវិទ្យាអាស៊ានដែលអាចប្រើជាមុខចូលក្នុងយុទ្ធសាស្ត្រអភិវឌ្ឍធនធានមនុស្ស ដោយអ្នកធ្វើផែនការសេដ្ឋកិច្ច និងឧស្សាហកម្ម<br>៣.ដំណើរការបណ្តាញទំនាក់ទំនង ASTNET ធ្វើជាមជ្ឈមណ្ឌលចែករំលែកព័ត៌មានវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា និងការសម្របសម្រួលបច្ចេកវិទ្យា<br>៤.ពង្រីកហេដ្ឋារចនាសម្ព័ន្ធព័ត៌មានអាស៊ាន តាមរយៈការបង្កើត និងប្រើប្រាស់អាតិការបស់ ASTNET, ITTIN, ASTMIS, ASTRENA និងធនធានផ្សេងទៀតរបស់គណៈកម្មាធិការវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា<br>៥.អភិវឌ្ឍគោលនយោបាយ និងប្រព័ន្ធ ដើម្បីធ្វើឱ្យប្រសើរឡើង និងគ្រប់គ្រងសហគ្រាសវិទ្យាសាស្ត្រនិងបច្ចេកវិទ្យាថ្នាក់តំបន់ រួមទាំងកិច្ចការពារកម្មសិទ្ធិបញ្ញាសម្រាប់ក្រុមហ៊ុនបង្កើត ថ្មី (Spin-offs) និងក្រុមហ៊ុនដែលបណ្តាក់ទុនរួមជាមួយគេ (Joint ventures)<br>៦.អភិវឌ្ឍក្របខណ្ឌការងារសម្រាប់បង្កើត |

| | | | |
|---|---|---|---|
| | | ៦.អនុវត្តគម្រោងសន្ទនាអាស៊ានជួយអាស៊ាន តាមប្រព័ន្ធព័ត៌មានវិទ្យា (ASEAN-help-ASEAN e-Conversation Projects) នៅក្នុងប្រទេសសមាជិកថ្មីរបស់អាស៊ាន ដោយផ្តោតជាបឋមទៅលើវិស័យវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា និងអប់រំ | **សហគ្រាសបច្ចេកវិទ្យាអាស៊ាន សម្រាប់ការស្រាវជ្រាវនវានុវត្តន៍សេវាកម្ម និងចំណេះដឹង** (ASTERISK) ដើម្បីបង្កើតសហគ្រាសវិទ្យាសាស្ត្រដែលមានសំទុះលឿនទៅមុខ បត់បែនងាយស្រួល និងមានទស្សនវិស័យច្បាស់លាស់ |
| | **យុទ្ធសាស្ត្រទី៦៖**<br>**លើកកម្ពស់ការបញ្ជ្រាបការយល់ដឹងវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា**<br><br>**សកម្មភាព៖**<br>១.ធ្វើការទទួលស្គាល់ការចូលរួមវិភាគទានរបស់អ្នកប្រតិបត្តិផ្ទាល់ និងរួមគ្នា ទៅក្នុងកិច្ចប្រឹងប្រែងផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាអាស៊ាន<br>២.ធ្វើការបោះពុម្ពផ្សាយព្រឹត្តិប័ត្រព័ត៌មាន និងទស្សនាវដ្តីវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាអាស៊ាន | Thrust 6: **ធ្វើការបង្កើតចំណូលតាមរយៈប្រព័ន្ធគ្រប់គ្រងនវានុវត្តន៍ និងការបង្កើតសហគ្រាស**<br><br>**សកម្មភាព៖**<br>១.ធ្វើការបង្កើតថ្មីនូវផ្នែកនៃការធ្វើពាណិជ្ជកម្មរបស់បណ្តាញទំនាក់ទំនងវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាអាស៊ាន(ASTNET)និងអភិវឌ្ឍវាឱ្យទៅជាសហគ្រាសបង្កើតចំណូល និងទៅជាមូលដ្ឋានសាកល្បងសម្រាប់គម្រោងនៅពេលអនាគត<br>២.អភិវឌ្ឍផែនការធុរកិច្ចឱ្យទៅជាគម្រោងបង្កើតថ្មីរបស់គណៈកម្មាធិការវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាដែលអាចជាសក្តានុពលនៃការចូលរួមដើមទុន<br>៣.បង្កើតឱ្យមានជាសហគ្រាសថ្មីដែលជាប្រព័ន្ធរបស់រដ្ឋរបស់គណៈកម្មាធិការវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា<br>៤.អភិវឌ្ឍប្រព័ន្ធចែករំលែកផលចំណេញដល់អ្នកស្រាវជ្រាវ វិទ្យាស្ថាន និងគណៈកម្មាធិការវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាអាស៊ាន<br>៥.បង្កើនថវិកាដែលរកបានពីការបង់ថ្លៃ និងការបង់ | Thrust 6: **ព្យាយាមធ្វើកិច្ចសហប្រតិបត្តិការជាមួយដៃគូចរចានិងស្ថាប័នផ្សេងទៀតលើការងារគម្រោងថ្នាក់តំបន់**<br><br>**សកម្មភាព៖**<br>១.អភិវឌ្ឍយុទ្ធសាស្ត្រថ្មីសម្រាប់ភាពជាដៃគូជាមួយដៃគូចរចាអំពីគម្រោងដែលនឹងផ្តល់ផលប្រយោជន៍ទាំងសងខាង<br>២.សម្របសម្រួលការងារចូលទៅកាន់ធនធានរបស់ដៃគូចរចា ដើម្បីដំណើរការគម្រោងថ្នាក់តំបន់ ដោយផ្តោតប្រទេសសមាជិកថ្មីរបស់អាស៊ាន<br>៣.ព្យាយាមធ្វើកិច្ចសហប្រតិបត្តិការឱ្យបានជិតជាមួយទីភ្នាក់ងារពាក់ព័ន្ធវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាដែលជាដៃគូបូកបី សម្រាប់ការអភិវឌ្ឍដែលផ្តល់អត្ថប្រយោជន៍ទាំងសងខាងនៅក្នុងអាស៊ីខាងកើត |

| | | | |
|---|---|---|---|
| | | តម្លៃសិទ្ធ (Fees and Royalties) ស្មើគ្នាចូលទៅក្នុងមូលនិធិវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាអាស៊ាន (ASF) សម្រាប់ការចាប់ផ្តើមរបស់គណៈកម្មាធិការ COST ។ | |
| | | **Thrust 7: គៀងគរដៃគូចរចារទៅតាមរបៀបរបបដែលបានកំណត់ នៅក្នុងវិស័យនៃកម្មវិធីសំខាន់ៗ និងក្នុងគម្រោង Flagship projects**<br>***<u>សកម្មភាព៖</u>***<br>១.ស្វែងរកតំណាងដ៏សមរម្យដើម្បីធ្វើការជជែកពិភាក្សាជាមួយដៃគូចរចារអំពីកិច្ចសហប្រតិបត្តិការវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា<br>២.អភិវឌ្ឍយុទ្ធសាស្ត្រសម្រាប់គៀងគរដៃគូចរចារក្នុងការរៀបចំគម្រោងសម្រាប់វិធីសាស្ត្រផ្សេងទៀតដែលនឹងទទួលបានផលប្រយោជន៍ទាំងសងខាង (ក្រៅពីការរៀបចំ និងតាមដានត្រួតពិនិត្យគម្រោង)<br>៣.អញ្ជើញដៃគូចរចារម្នាងទៀត និងវិស័យឯកជនធ្វើការអភិវឌ្ឍដោយមានចំណែកហ៊ុនរួមគ្នា<br>៤.សម្របសម្រួលការចូលទៅកាន់ធនធានដៃគូចរចារសម្រាប់អនុវត្តគម្រោងថ្នាក់តំបន់ដោយផ្តោតទៅលើប្រទេសសមាជិកថ្មីរបស់អាស៊ាន<br>៥.ចាត់ចែងគ្រប់គ្រងទំនាក់ទំនង COST+3 ក្នុងទស្សនៈភាពជាដៃគូជិតស្និទ្ធ សម្រាប់ការអភិវឌ្ឍដែលផ្តល់ផលប្រយោជន៍ទាំងសងខាងនៅក្នុងអាស៊ីខាងកើត ។ | |
| | | **Thrust 8: គ្រប់គ្រងសហគ្រាសវិទ្យាសាស្ត្រ និងបច្ចេកវិទ្យានៅក្នុងការអភិវឌ្ឍសហសវត្ស** | |

| | | | |
|---|---|---|---|
| | | <u>**សកម្មភាព៖**</u><br>១.អភិវឌ្ឍប្រព័ន្ធនវានុវត្តន៍ដើម្បីចាត់ចែងគ្រប់គ្រង វិទ្យាសាស្ត្រ និងបច្ចេកវិទ្យាថ្នាក់តំបន់ សហគ្រាសបច្ចេកវិទ្យាដែលមានចំណាប់អារម្មណ៍ច្រើនមុខទៅលើការស្រាវជ្រាវ និងអភិវឌ្ឍន៍ ការបង្កើតសហគ្រាសថ្មី និងការអភិវឌ្ឍដែលមានទុនរួមគ្នា (Venture development)<br>២.អភិវឌ្ឍយន្តការនវានុវត្តន៍សម្រាប់គណៈកម្មាធិការវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ដើម្បីប្រកាន់យកភាពស្មើគ្នានៅក្នុងសហគ្រាសបង្កើតថ្មី និងការចូលរួមទុនជាមួយគ្នារបស់គេ | |

## II. ការចូលរួមចំណែកនិងក្របខណ្ឌការងារសំខាន់ៗ សម្រាប់អភិវឌ្ឍផែនការសកម្មភាពអាស៊ានផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ២០១៦-២០២៥ (APASTI 2016-2025)

ក្នុងការអភិវឌ្ឍ និងអនុវត្តកន្លងមក ផែនការសកម្មភាពអាស៊ានផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា តែងតែត្រូវបានដឹកនាំតម្រង់ទិសដោយសេចក្តីបង្គាប់ការរបស់ថ្នាក់ដឹកនាំអាស៊ាន ដោយឈរលើគោលការណ៍កិច្ចសហប្រតិបត្តិការអាស៊ាន ចក្ខុវិស័យអាស៊ានឆ្នាំ២០២០ និងផែនការសកម្មភាពជាបន្តបន្ទាប់ (ដូចជាផែនការសកម្មភាព HPA1999-2004, VAP2004-2010 ផែនទីបង្ហាញផ្លូវសម្រាប់សហគមន៍អាស៊ាន ២០០៩-២០១៥) និងសេចក្តីប្រកាសមួយចំនួន (Declarations) ដើម្បីសម្រេចតាមគោលដៅ និងបំណងប្រាថ្នាឆ្ពោះទៅរកការបង្កើតសហគមន៍អាស៊ាន ។

មគ្គុទ្ទេស និងការតំរង់ផ្លូវរបស់គណៈកម្មាធិការវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា និងកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីអាស៊ានផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា រួមទាំងភាពជោគជ័យ និងបទពិសោធន៍ទទួលបានពីការអនុវត្ត**ផែនការសកម្មភាពអាស៊ានផ្នែក វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា** (APAST) កន្លងមក បានកំណត់ច្បាស់ថាតើបន្ទាប់មកត្រូវអភិវឌ្ឍយ៉ាងដូចម្តេច ។ បើសិនមិនគិតរួមបញ្ចូលនូវនវានុវត្តន៍ទេ នោះការអភិវឌ្ឍ**ផែនការសកម្មភាពអាស៊ានផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍** (APASTI) ២០១៦-២០១៥ នឹងមិនងាកចេញពីអ្វីដែលត្រូវបានវាយតម្លៃថាធ្វើបានប្រសើរបំផុតពីមុនមកទេ ។ ជាមួយគ្នានេះ នៅពេល Strategic Thrusts និងសកម្មភាពអនុវត្តដែលពាក់ព័ន្ធនៅក្នុងផែនការសកម្មភាពអាស៊ានផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា (APAST) កន្លងមក នៅបន្តសុពលភាព នោះអាចនឹងត្រូវកំណត់វិធីសាស្ត្រ និងយុទ្ធសាស្ត្រថ្មីៗ ហើយអាចនឹងត្រូវកំណត់ប្រសិទ្ធិភាពការងារយ៉ាងដូចម្តេច ក្នុងការអនុវត្តសកម្មភាពជាក់លាក់ ។

ដូច្នេះ ការអភិវឌ្ឍផែនការសកម្មភាពអាស៊ានផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ២០១៦-២០២៥ (APASTI 2016-2025) ត្រូវបានតម្រង់ទិសដោយការសម្រេចចិត្ត និងសកម្មភាពសំខាន់ៗដូចខាងក្រោម៖

**១. សេចក្តីសម្រេចរបស់កិច្ចប្រជុំក្រៅផ្លូវការលើកទី៦ ថ្នាក់រដ្ឋមន្ត្រីវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាអាស៊ាន (6th IAMMAST) ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១០ នៅក្រាប៊ី (Krabi) ប្រទេសថៃ ។**

*កិច្ចផ្តួចផ្តើមទីក្រុងក្រាប៊ី (Krabi Initiative-KI) ដែលត្រូវបានសម្រេចទទួលយកនៅពេលនោះ គឺក្រោមបរិបទ* ***វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ (STI) សម្រាប់ការប្រកួតប្រជែង និរន្តរភាព និងបរិយាប័ន្នអាស៊ាន (Science, Technology and Innovation-STI for a Competitive, Sustainable and Inclusive ASEAN)*** *ហើយកិច្ចផ្តួចផ្តើមក្រាប៊ី (KI) បានដាក់ចេញនូវក្របខណ្ឌការងារ ថាតើអាស៊ានត្រូវរៀបចំដូចម្តេចសម្រាប់អនាគតវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ចាប់ពីឆ្នាំ២០១៥ ទៅមុខ ។*

*ដើម្បីសម្រេចបាននូវសេចក្តីសម្រេចនេះ KI បានដាក់ចេញនូវ Thematic Tracks ចំនួន៨ ដូចខាងក្រោម៖*

- i. *នវានុវត្តន៍អាស៊ានសម្រាប់ទីផ្សារសកល (ASEAN Innovation for Global Market)*
- ii. *សេដ្ឋកិច្ចអេឡិចត្រូនិក និងបណ្តាញទំនាក់ទំនងសង្គម និងព័ត៌មានថ្មី (Digital Economy, New Media and Social Networking)*
- iii. *បច្ចេកវិទ្យាបៃតង (Green Technology)*
- iv. *សន្តិសុខស្បៀង (Food Security)*
- v. *សន្តិសុខថាមពល (Energy Security)*
- vi. *ការគ្រប់គ្រងធនធានទឹក (Water Management)*
- vii. *ជីវៈចម្រុះសម្រាប់សុខភាព និងសុខុមាលភាព (Biodiversity for Health and Wealth)*
- viii. *វិទ្យាសាស្ត្រ និងនវានុវត្តន៍សម្រាប់ជីវិត និងការរស់នៅ (Science and Innovation for Live) ។*

**២. សេចក្តីសម្រេចនៃកិច្ចប្រជុំលើកទី១៤ថ្នាក់រដ្ឋមន្ត្រីវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាអាស៊ាន (14th AMMST) ថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១១ នៅទីក្រុងហូជីមិញ ប្រទេសវៀតណាម ។**

*កិច្ចប្រជុំបានកត់សំគាល់ទៅលើចំណុចសំខាន់ៗដែលបានរកឃើញ និងអនុសាសន៍នៃការសិក្សាអំពីស្ថានភាពនៃការអភិវឌ្ឍវិទ្យាសាស្ត្រ និងបច្ចេកវិទ្យានៅតាមប្រទេសសមាជិកអាស៊ាន (Study on the State of S&T Development in ASEAN) ។*

**៣. សេចក្តីសម្រេចនៃកិច្ចប្រជុំក្រៅផ្លូវការលើកទី៧ ថ្នាក់រដ្ឋមន្ត្រីវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាអាស៊ាន (7th IAMMST) ថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១២ នៅទីក្រុងហ្សេរ៊ុយដុង ប្រទេសប្រ៊ុយណេ ។**

*កិច្ចប្រជុំបានកត់សំគាល់ទៅលើសំណើធ្វើការកែសម្រួលរចនាសម្ព័ន្ធគណៈកម្មាធិការវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា តាមរយៈការរៀបចំឱ្យមានជាកម្រង (Clusters) ទៅតាម Thematic Tracks នៃកិច្ចផ្តួចផ្តើមក្រាប៊ី ។ ក្នុងនោះមានការឯកភាពរបស់ថ្នាក់រដ្ឋមន្ត្រីថាចាំបាច់ត្រូវធ្វើឱ្យមានសង្គតភាពរវាងចំណុចទាំង៨ នៃ Thematic Tracks និងចំណុចទាំង៦ នៃ Flagship Programmes នៅមុនពេលកម្រងនេះត្រូវបានបង្កើតឡើង ។ ក្នុងកិច្ចប្រជុំនោះ ក្រុមប្រឹក្សាយោបល់លើផែនការសកម្មភាពអាស៊ាន ផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា និងក្រុមប្រឹក្សាយោបល់លើមូលនិធិវិទ្យាសាស្ត្រអាស៊ាន ហៅកាត់ថា ABAPAST និង ABASF ត្រូវបានសម្រេចឱ្យរួមគ្នាបង្កើតជាឯកសាររៀបចំគម្រោង (Concept Paper) នៃការបង្កើតមូលនិធិនវានុវត្តន៍អាស៊ាន (ASEAN Innovation Fund-AIF) សម្រាប់ជួយដល់ការអនុវត្តគម្រោងដែលនាំមុខដោយវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា និងនវានុវត្តន៍ (STI) ។*

**៤. សេចក្តីសម្រេចនៃកិច្ចប្រជុំលើកទី៦៥ របស់គណៈកម្មាធិការអាស៊ានផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា (65th COST Meeting) ថ្ងៃទី២៣-២៤ ខែឧសភា ឆ្នាំ២០១៣ នៅទីក្រុងតាហ្គាតៃ ប្រទេសហ្វីលីពីន ។**

*កិច្ចប្រជុំបានកត់សំគាល់ថាក្រោមផ័ត្រផែនទីបង្ហាញផ្លូវរបស់អាស៊ាន (ASEAN Roadmap) សម្រាប់កសាងសហគមន៍ ២០០៩-២០១៥ វិទ្យាសាស្ត្រ និងបច្ចេកវិទ្យាអាចរួមវិភាគទាន ឆ្ពោះទៅរកការស្ថាបនាសហគមន៍អាស៊ាន ដែលអាចដាក់បញ្ចូលក្នុងឯកសារ ASCC Blueprint ។ ក្នុងកិច្ចប្រជុំនេះ ក៏មានការឯកភាពផងដែរថាចាំបាច់ត្រូវរៀបចំផែនការសកម្មភាពអាស៊ានផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ (APASTI) ដែលនឹងមានគោលដៅ គោលបំណងជាយុទ្ធសាស្ត្រ (Strategic Thrusts) និងផែនការសកម្មភាព ដែលត្រូវគ្នាទៅនឹងខ្លឹមសារបរិបទ**សហគមន៍សេដ្ឋកិច្ចអាស៊ាន ក្រោយឆ្នាំ ២០១៥** (AEC post 2015) ។*

**៥. សេចក្តីសម្រេចនៃកិច្ចប្រជុំលើកទី១៥ ថ្នាក់រដ្ឋមន្ត្រីវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៣ នៅទីក្រុងគូឡាឡាំពួ ប្រទេសម៉ាឡេស៊ី ។**

*ក្នុងកិច្ចប្រជុំនេះ បានកត់សំគាល់ទៅលើអនុសាសន៍ណែនាំនៃកិច្ចប្រជុំ High-Level Task Force (HLTF) លើការពង្រឹងលេខាធិការដ្ឋានអាស៊ាន និងពិនិត្យឡើងវិញនូវតួអង្គអាស៊ាន និងឱ្យជំនាញការដែលរៀបចំផែនការសកម្មភាពអាស៊ានផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍២០១៥-២០២០ ពិនិត្យមើលឡើងវិញពីប្រសិទ្ធភាព និងភាពសក្តិសិទ្ធនៃដំណើរការការងាររបស់គណៈកម្មាធិការអាស៊ានផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា (ASEAN COST) ។*

*ក្នុងពេលនោះ ក៏មានការកត់សំគាល់ទៅលើសំណើរបស់ High-Level Task Force on Economic Integration (HLTF-EI) លើការបង្រួមខ្លឹមសារចក្ខុវិស័យរបស់AEC post 2015 ដែលមានសរសេរស្តម្ភចំនួន៤គឺ៖*

*(i) សេដ្ឋកិច្ចដែលបានធ្វើសមាហរណកម្ម និងមានការរួបរួមគ្នា (Integrated and Cohesive Economy)*

*(ii) អាស៊ានដែលមានថាមពល ការប្រកួតប្រជែង និងការច្នៃប្រឌិតបង្កើតថ្មី*

*(iii) អាស៊ានដែលគិតពីមនុស្សជាមូលដ្ឋាន និងប្រកបដោយភាពធន់ទ្រាំ*

*(iv) ពង្រឹងការធ្វើសមាហរណកម្មអាស៊ានជាសកល និងកិច្ចសហប្រតិបត្តិការតាមវិស័យ ។*

*ក្នុងកិច្ចប្រជុំនោះ ថ្នាក់រដ្ឋមន្ត្រីបានសម្រេចឯកភាពទៅលើសំណើចក្ខុវិស័យ និងគោលដៅអំពីវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ដែលអាចត្រូវបានចែងនៅក្នុងសរសេរស្តម្ភទី៤ នៃ**សហគមន៍សេដ្ឋកិច្ចអាស៊ានក្រោយឆ្នាំ ២០១៥** (AEC Post 2015)៖*

***ចក្ខុវិស័យ***

*"វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ដែលជួយដល់អាស៊ានឱ្យប្រកបដោយការច្នៃប្រឌិតបង្កើតថ្មី ការប្រកួតប្រជែង មានភាពរស់រវើក និងប្រកបដោយសមាហរណកម្មសេដ្ឋកិច្ច និងចីរភាព" (A Science, Technology and Innovation-enable ASEAN which is innovative, competitive, vibrant, sustainable and economically integrated)*

***គោលដៅ***

*(i) អាស៊ានដែលមានសមាហរណកម្មសេដ្ឋកិច្ច និងមានការចូលរួមសហប្រតិបត្តិការយ៉ាងសកម្មរវាងវិស័យសាធារណៈ និងឯកជន និងមានការចល័តអ្នកមានទេពកោសល្យ*

*(ii) បញ្ជ្រាបការយល់ដឹងឱ្យបានទូលំទូលាយអំពីវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ (STI) និងឥទ្ធពលដែលមានសារៈប្រយោជន៍របស់ STI ដល់ផ្នែកមូលដ្ឋាននៃពីរ៉ាមីដ*

*(iii) សេដ្ឋកិច្ចដែលនាំមុខដោយនវានុវត្តន៍ផ្អែកលើបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន (ICT) និងមានការចូលរួមយ៉ាងរឹងមាំក្នុងផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ពីសំណាក់យុវវ័យរបស់អាស៊ាន*

*(iv) នវានុវត្តន៍អាស៊ានដែលតាមទាន់ទីផ្សារសកល*

*(v) នវានុវត្តន៍អាស៊ានដែលឆ្លើយតបទៅនឹងកាលានុវត្តភាពធំៗរបស់សហសវត្សថ្មី*

*(vi) កិច្ចសហប្រតិបត្តិការស្រាវជ្រាវ និងអភិវឌ្ឍន៍យ៉ាងសកម្ម ការធ្វើពាណិជ្ជកម្មបច្ចេកវិទ្យា (ឬការនាំបច្ចេកវិទ្យាទៅកាន់ទីផ្សារ) សហគ្រិនភាព និងបណ្តាញទំនាក់ទំនងរបស់មជ្ឈមណ្ឌលឧត្តមភាព ។*

*កិច្ចប្រជុំបានគាំទ្រទៅលើសំណើធ្វើវិសោធនកម្មសេចក្តីណែនាំ និងឯកភាពទៅលើការប្តូរឈ្មោះ **មូលនិធិវិទ្យាសាស្ត្រអាស៊ាន (ASF)** ទៅជា **មូលនិធិវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍អាស៊ាន (ASTIF)** ។*

**៦. សេចក្តីសម្រេចនៃកិច្ចប្រជុំលើកទី៦៩ របស់គណៈកម្មាធិការវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៥ នៅទីក្រុងភូកេត ប្រទេសថៃ ។**

*កិច្ចប្រជុំលើកទី៦៩ របស់គណៈកម្មាធិការវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា បានឯកភាពទៅលើការកែសម្រួលអណត្តិនៃការអនុវត្តផែនការសកម្មភាពអាស៊ានផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្ត៍ (APASTI) ពីឆ្នាំ២០១៥-២០២០ ទៅជា ២០១៦-២០២៥ ដើម្បីឱ្យត្រូវគ្នាទៅនឹងរយៈពេលនៃការអនុវត្តរបស់**ឯកសារសហគមន៍សេដ្ឋកិច្ចអាស៊ានក្រោយឆ្នាំ២០១៥ (AEC Post 2015 Attendant Document)** ។*

*កិច្ចប្រជុំក៏បានឯកភាពទៅលើការធ្វើការកែសម្រួលខ្លឹមសារគោលដៅ៦ ចំណុច របស់ផែនការសកម្មភាពអាស៊ានផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្ត៍ និងបានសម្រេចទទួលយកនូវសំណើវិធីសាស្ត្រ/វិធាន STI នៅក្នុងឯកសារសហគមន៍សេដ្ឋកិច្ចអាស៊ានក្រោយឆ្នាំ២០១៥ ទៅលើចំណុច D (Element D) និង F (Element F) ។*

*កិច្ចប្រជុំក៏បានឯកភាពផងដែរថា **ផែនការសកម្មភាពលំអិតរបស់ APASTI 2016-2025** នឹងត្រូវបង្កើតឡើងឱ្យបានឆាប់នៅពេលដែល **APASTI 2016-2025** ត្រូវបានសម្រេចដោយថ្នាក់រដ្ឋមន្ត្រី ។*

**៧. សេចក្តីសម្រេចនៃកិច្ចប្រជុំលើកទី១៦ ថ្នាក់រដ្ឋមន្ត្រីអាស៊ាន AMMST-16, Vientiane, Lao PDR, 6 Nov 2015**

*ថ្នាក់រដ្ឋមន្ត្រីបានសម្រេចទទួលយក APASTI 2016-2025 និងបានគូសបញ្ជាក់នូវភាពត្រូវការចាំបាច់ និងបន្ទាន់សម្រាប់កម្មវិធី និងសកម្មភាពច្បាស់លាស់របស់ COST ដើម្បីទទួលបានការចាប់អារម្មណ៍ និងលើកសរសើរពីថ្នាក់ដឹកនាំរបស់អាស៊ាន ។ រដ្ឋមន្ត្រីបានគាំទ្រអនុសាសន៍របស់ APASTI ក្នុងការធ្វើកំណែទម្រង់គណៈកម្មាធិការ*

*អាស៊ានផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា (COST) ដោយធ្វើការបញ្ចូលគ្នានូវក្រុមប្រឹក្សាយោបល់ ABAPAST និង ABASF ឱ្យទៅជាក្រុមប្រឹក្សាផ្ដល់យោបល់ឱ្យ COST (Board of Advisers to COST – BAC) និងបានសម្រេចឱ្យលេខាធិការដ្ឋានអាស៊ានរៀបចំ TOR សម្រាប់ BAC ដែល BAC នឹងក្លាយជាតួអង្គរឹងមាំ និងយ៉ាងសកម្មរបស់ COST។ រដ្ឋមន្ត្រីបានឯកភាពថា APASTI ត្រូវមានផែនការអនុវត្តភ្ជាប់ជាមួយ ដែលនឹងរួមបញ្ចូលនូវអាទិភាព ក្រុមគោលដៅ សកម្មភាពជាក់លាក់ ពេលវេលា និងសូចនាករ ដែលទាំងអស់នេះ នឹងត្រូវបង្កើតឡើងដោយអង្គភាពទាំងអស់របស់ COST ។ ជាមួយគ្នានេះ លេខាធិការដ្ឋានអាស៊ានត្រូវបង្កើតតារាងគម្រូដែលត្រូវបំពេញ និងចែកជូនដល់គ្រប់អង្គភាពរបស់ COST ដើម្បីជាឯកសារយោងសម្រាប់បង្កើតផែនការការងារ ។*

តាមរយៈលិខិតលេខ MITI.600-5/4/6 ចុះថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០១៥ របស់ឯកឧត្តម **DATO' SRI MUSTAPA MOHAMED** រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និងឧស្សាហកម្មអន្តរជាតិម៉ាឡេស៊ី និងជារដ្ឋមន្ត្រីវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាអាស៊ាន ឆ្នាំ២០១៥ ផ្ញើរជូនឯកឧត្តមបណ្ឌិតសាស្ត្រាចារ្យ H.E Prof. Dr. Borviengkham Vongdara រដ្ឋមន្ត្រីក្រសួងវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ប្រទេសឡាវ និងជាប្រធាន AMMST-16 បានលើកឡើងពីការកត់សំគាល់របស់ក្រុមប្រឹក្សារដ្ឋមន្ត្រីសហគមន៍សេដ្ឋកិច្ចអាស៊ាន (AEC Council Ministers) នៅក្នុងកិច្ចប្រជុំកំពូលអាស៊ានលើកទី២៧ នូវកិច្ចខិតខំប្រឹងប្រែងរបស់អង្គភាពតាមវិស័យមួយចំនួន ដែលបានអភិវឌ្ឍ**ផែនការការងារតាមវិស័យ**របស់ខ្លួន (Sectoral Work Plan-SWP) សម្រាប់ AEC Blueprint 2025 ដែលជាតម្រូវការចាំបាច់បំផុត និងស្នើសុំឱ្យគ្រប់អង្គភាពផ្សេងទៀតក្រោមឆ័ត្រសហគមន៍សេដ្ឋកិច្ចអាស៊ាន (AEC) រៀបចំ SWP នេះ ឱ្យបានត្រឹមខែមេសា ឆ្នាំ២០១៦ ខាងមុខ ។

បន្តតាមលិខិតខាងលើលេខាធិការដ្ឋានអាស៊ានបានផ្ញើរសារអេឡិចត្រូនិកជូនឯកឧត្តមប្រធានគណៈកម្មាធិការជាតិ NCOST គ្រប់ប្រទេសសមាជិកអាស៊ាន និងជនបង្គោល NCOST ហើយបានគូសបញ្ជាក់ថា SWP ដែលបានលើកឡើង ដោយរដ្ឋមន្ត្រីប្រទេសម៉ាឡេស៊ី គឺសំដៅទៅលើផែនការសកម្មភាពសម្រាប់អនុវត្ត (Implementation Plan) របស់គ្រប់អង្គភាពរបស់ COST នេះឯង ហើយលេខាធិការដ្ឋានអាស៊ានបានបញ្ជូនតារាងបំពេញព័ត៌មានសម្រាប់ផែនការការងាររបស់គ្រប់អនុគណៈកម្មការទាំង៩ (នៅថ្ងៃ១៥ ខែមករា ឆ្នាំ២០១៦) និងបានស្នើសុំឱ្យ NCOST ផ្សព្វផ្សាយដល់គ្រប់អនុគណៈកម្មការ ធ្វើការរៀបចំផែនការសកម្មភាព (SC Work Plan) រៀងខ្លួន ។ អនុគណៈកម្មការទាំងអស់នឹងធ្វើការជួបប្រជុំគ្នានៅដើមឆ្នាំ២០១៦ នេះ ដើម្បីពិភាក្សាផ្ដល់យោបល់ និងបញ្ចប់នូវផែនការសកម្មភាពរបស់គេ ។ សម្រាប់រៀបចំផែនការសកម្មភាពរបស់អនុគណៈកម្មការ (Sub-Committees) លេខាធិការដ្ឋានអាស៊ានបានបញ្ជូនឯកសារណែនាំ (Proposed Guidelines) សម្រាប់ការវិភាគ Logic Analysis និងតារាងផែនការសកម្មភាព (Implementation Plan) ដែលមាន Template សម្រាប់បំពេញផែនការសកម្មភាព ឬគម្រោងជាក់លាក់របស់អនុគណៈកម្មការរបស់អនុគណៈកម្មការ (ឯកសារភ្ជាប់ជាមួយ) ។

## III. ផែនការសកម្មភាពអាស៊ានផ្នែក វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ២០១៦-២០២៥

ផ្អែកតាម Milestones និងលទ្ធផលសំខាន់ៗដែលសម្រេចបាន មេរៀន និងបទពិសោធន៍ទទួលបានពីការអនុវត្តផែនការសកម្មភាព APAST កន្លងមក និងដោយផ្ដោតយ៉ាងរឹងមាំលើវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា នោះតួនាទី និងអត្ថប្រយោជន៍របស់នវានុវត្តន៍នៅក្នុងផែនការសកម្មភាពអាស៊ានផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ២០១៦-២០២៥ (APASTI 2016-2025) នឹងជួយដល់ប្រជាពលរដ្ឋអាស៊ាន ក្នុងការសម្រេចបានជោគជ័យថ្មី ។ ស្ថិតក្រោមការណែនាំនៃសេចក្ដីប្រកាសទាំងឡាយរបស់ថ្នាក់ដឹកនាំអាស៊ាន ការតម្រង់ទិសរបស់គណៈកម្មាធិការវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា និងរដ្ឋមន្ត្រីវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាអាស៊ាន និងវឌ្ឍភាពថ្មីៗរបស់អាស៊ាន នោះផែនការសកម្មភាពអាស៊ានផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ឆ្នាំ២០១៦-២០២៥ មានចក្ខុវិស័យ គោលដៅ គោលបំណងជាយុទ្ធសាស្ត្រ និងសកម្មភាព ដូចខាងក្រោម៖

**១.ចក្ខុវិស័យ APASTI 2016-2015**

សហគមន៍អាស៊ានដែលប្រកបដោយសមត្ថភាពខាងវិស័យវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ មានលក្ខណៈថ្មៃប្រឌិត-បង្កើតថ្មី ប្រកួតប្រជែង រស់រវើក ចីរភាព និងសមាហរណកម្មសេដ្ឋកិច្ច ។

**២.គោលដៅ APASTI 2016-2015**

1. វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍អាស៊ានដែលឆ្លើយតបទៅនឹងកាលានុវត្តភាពធំៗរបស់សហសវត្សថ្មី
2. អាស៊ានដែលមានសមាហរណកម្មសេដ្ឋកិច្ច និងមានការចូលរួមសហប្រតិបត្តិការយ៉ាងសកម្មរវាងវិស័យសាធារណៈ និងឯកជន ជាពិសេសសហគ្រាសធុនតូច និងមធ្យម ព្រមទាំងមានការចល័តអ្នកមានទេពកោសល្យ
3. បញ្ជ្រាបការយល់ដឹងឱ្យបានទូលំទូលាយអំពីវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ (STI) និងឥទ្ធិពលដែលមានសារៈប្រយោជន៍របស់ STI ដល់**ផ្នែកមូលដ្ឋាន**នៃពីរ៉ាមីដ
4. សេដ្ឋកិច្ចដែលនាំមុខដោយនវានុវត្តន៍ ជាមួយនិងការចាក់រឹសរឹងមាំនៃការបណ្តុះគ្រាប់ និងសាបព្រោះ STI និងធ្វើឱ្យមានចេរភាពដំណើរការវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ដោយលើកកម្ពស់បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន (ICT) និងធនធានដែលជាអ្នកមានទេពកោសល្យវ័យក្មេង និងស្ត្រី និងវិស័យឯកជន
5. ជម្រុញយ៉ាងសកម្មនូវកិច្ចសហប្រតិបត្តិការស្រាវជ្រាវ និងអភិវឌ្ឍន៍ ការធ្វើពាណិជ្ជកម្មបច្ចេកវិទ្យាសហគ្រិនភាព និងបណ្តាញទំនាក់ទំនងរបស់មជ្ឈមណ្ឌលឧត្តមភាព
6. ប្រព័ន្ធដ៏ទូលំទូលាយមួយគ្រប់គ្រងវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍នៅក្នុងសហគមន៍សេដ្ឋកិច្ចអាស៊ានថ្មី ដើម្បីជួយដល់នវានុវត្តន៍អាស៊ានឱ្យបានតាមទាន់ទីផ្សារសកល និងលើកកម្ពស់នវានុវត្តន៍ និងសមាហរណកម្ម និងបង្រួមនូវភាពគំលាតនៃការអភិវឌ្ឍរវាងប្រទេសសមាជិកអាស៊ាន ។

**៣.គោលបំណងជាយុទ្ធសាស្ត្រ (Strategic Thrusts) និងសកម្មភាព**

ដោយទទួលស្គាល់ថាគោលបំណងជាយុទ្ធសាស្ត្រ និងសកម្មភាពរបស់ APAST កន្លងមក នៅមានសុពលភាពនៅឡើយ នោះគោលបំណងជាយុទ្ធសាស្ត្រ និងសកម្មភាពដូចខាងក្រោម ត្រូវបានរៀបចំឡើងដោយមានការរួមវិភាគទានអំពីយុទ្ធសាស្ត្រ ការវិភាគ អនុសាសន៍ និងហេតុផលសំខាន់ៗជាច្រើន ដែលនឹងបង្កើតចេញនូវសម្លេងរួមសម្រាប់អនុវត្ត ។

Thrust 1: **ពង្រឹងកិច្ចសហប្រតិបត្តិការជាយុទ្ធសាស្ត្ររវាងគ្រឹះស្ថានអប់រំ វិទ្យាស្ថានស្រាវជ្រាវ បណ្តាញទំនាក់ទំនងរបស់មជ្ឈមណ្ឌលឧត្តមភាព និងវិស័យឯកជន ដើម្បីបង្កើតប្រព័ន្ធអេកូឡូស៊ីមួយដ៏មានប្រសិទ្ធិភាពសម្រាប់ការអភិវឌ្ឍសមត្ថភាព ការផ្ទេរបច្ចេកវិទ្យា និងការធ្វើពាណិជ្ជកម្មបច្ចេកវិទ្យា ។**

**សកម្មភាពទី១៖**

ជម្រុញឱ្យមានការចូលរួមពីសំណាក់គ្រឹះស្ថានអប់រំ វិស័យឯកជន និងដៃគូពាក់ព័ន្ធ នៅក្នុងការធ្វើផែនការ ការអនុវត្ត និងការវាយតម្លៃ នៅក្នុងការអភិវឌ្ឍធនធានមនុស្ស និងការស្រាវជ្រាវ និងអភិវឌ្ឍន៍ ។

**សកម្មភាពទី២៖**

ពង្រីក និងធ្វើឱ្យមានចេរភាពនូវការប្រើប្រាស់បណ្តាញទំនាក់ទំនងវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាអាស៊ាន(ASTNET) និងពង្រឹងបណ្តាញទំនាក់ទំនងវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ដ៏ទៃទៀត ដើម្បីសម្របសម្រួលការចែករំលែកព័ត៌មាន។

**សកម្មភាពទី៣៖**

បង្កើតក្របខណ្ឌការងារគោលនយោបាយ រួមទាំងការការពារកម្មសិទ្ធបញ្ញា យន្តការចែករំលែកព័ត៌មានអំពីហានិភ័យ និងអត្ថប្រយោជន៍ សម្រាប់កិច្ចសហប្រតិបត្តិការរួមគ្នា និងការផ្ទេរបច្ចេកវិទ្យាក្នុងចំណោមមជ្ឈមណ្ឌល

ឧត្តមភាព ។

**សកម្មភាពទី៤៖**

ពង្រឹងសកម្មភាពផ្តួចផ្តើមវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ថ្នាក់តំបន់ដែលកំពុងមានស្រាប់ នៅក្នុងវិស័យជាអាទិភាពរួមទាំងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ។

**Thrust 2: ពង្រីកការចល័តអ្នកវិទ្យាសាស្ត្រ និងអ្នកស្រាវជ្រាវ ការភ្ជាប់ទំនាក់ទំនងមនុស្សនឹងមនុស្ស (People-to-people Connectivity) និងពង្រីកការចូលរួមរបស់ស្ត្រី និងយុវវ័យក្នុងផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍**

**សកម្មភាពទី១៖**

បង្កើតក្របខណ្ឌការងារគោលនយោបាយសម្រាប់ផ្លាស់ប្តូរអ្នកវិទ្យាសាស្ត្រ អ្នកស្រាវជ្រាវ និងនិស្សិត រួមទាំងស្ត្រី និងយុវវ័យ ។

**សកម្មភាពទី២៖**

បង្កើតអាហារូបករណ៍ និងកម្មវិធីផ្តល់អាហារូបករណ៍ និងកម្មវិធីពាក់ព័ន្ធសម្រាប់និស្សិត អ្នកស្រាវជ្រាវ និងបុគ្គលិកវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ (STI Personnel) ផ្សេងទៀត ។

**សកម្មភាពទី៣៖**

ជម្រុញការធ្វើស្តង់ដារូបណីយកម្មនៃការផ្តល់វិញ្ញាបនប័ត្រ និងការវាយតម្លៃទទួលស្គាល់ នៅក្នុងការសិក្សាអប់រំ និងសមត្ថកិច្ចបច្ចេកទេស ។

**សកម្មភាពទី៤៖**

ពង្រីកកាលានុវត្តភាពសម្រាប់ស្ត្រី យុវវ័យ និងក្រុមដែលពុំមានប្រៀបឈ្នះ ដើម្បីឱ្យពួកគេបានចូលរួមក្នុងសកម្មភាពវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ តាមរយៈការលើកទឹកចិត្ត និងយន្តការគាំទ្រផ្សេងៗ ។

**Thrust 3: បង្កើតប្រព័ន្ធនវានុវត្តន៍ និងភាពជាដៃគូឆ្លាតវៃ ជាមួយដៃគូចរចារ និងជាមួយដៃគូផ្សេងទៀត ដើម្បីបណ្តុះឱ្យមានឡើងនូវសហគ្រាស STI សម្រាប់គាំទ្រសហគ្រាសធុនតូច និងមធ្យម បណ្តុះឡើងនូវចំណេះដឹងបង្កើតថ្មី និងការអនុវត្តន៍វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍សម្រាប់ការប្រកួតប្រជែង ។**

**សកម្មភាពទី១៖**

បង្កើតយន្តការគាំទ្រ ដូចជាកម្មវិធីណែនាំ និងកម្មវិធីលើកទឹកចិត្ត ដើម្បីបង្កើតឱ្យមាន និងគាំទ្រដល់សហគ្រាស STI ចាប់ពីក្រុមហ៊ុនដែលទើបចាប់ផ្តើម ទៅកាន់កំរិតនៃការប្រកួតប្រជែងសម្រាប់អភិវឌ្ឍន៍

**សកម្មភាពទី២៖**

កៀងគរដៃគូចរចារ និងដៃគូជាយុទ្ធសាស្ត្រផ្សេងទៀតឱ្យចូលរួមក្នុងកិច្ចប្រតិបត្តិជាមួយគ្នា អំពីកិច្ចផ្តួចផ្តើមផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ដែលមានលក្ខណៈពាណិជ្ជកម្ម សមរម្យ និងរស់រវើក ។

**Thrust 4: បញ្ជ្រាបការយល់ដឹងដល់វិស័យសាធារណៈ និងពង្រឹងការបណ្តុះបណ្តាល STI ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាអាស៊ាន**

**សកម្មភាពទី១៖**

កៀងគរអ្នកវិទ្យាសាស្ត្រ អ្នកស្រាវជ្រាវ និងឧស្សាហកម្មឱ្យចូលរួមសកម្មភាពក្នុងព្រឹត្តិការណ៍វិទ្យាសាស្ត្រ និងបច្ចេកវិទ្យារបស់អាស៊ាន ដូចជាសន្និសីទចំណីអាហារ (ASEAN Food Conference-AFC) និងសប្តាហ៍វិទ្យាសាស្ត្រ និងបច្ចេកវិទ្យាអាស៊ាន (ASEAN Science and Technology Week-ASTW) ជាដើម ។

**សកម្មភាពទី២៖**
បង្កើនមាតិកា (បញ្ជីរឿង) នៃអត្ថបទដែលបានបោះពុម្ពផ្សាយនៅក្នុងទស្សនាវដ្តីអាស៊ានអំពីវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាសម្រាប់ការអភិវឌ្ឍ និងទស្សនាវដ្តីផ្សេងទៀត ។
**សកម្មភាពទី៣៖**
បង្កើនកម្លាំងបណ្តាញទំនាក់ទំនងវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាអាស៊ាន (ASTNET) ក្នុងការបោះពុម្ពផ្សាយសកម្មភាពផ្តួចផ្តើមរបស់អាស៊ានក្នុងផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ។
**សកម្មភាពទី៤៖**
អភិវឌ្ឍធនធានរៀបចំប្រព័ន្ធទិន្នន័យ និងបណ្តាញទំនាក់ទំនង ដើម្បីសម្របសម្រួលដល់ការចែករំលែកព័ត៌មាន និងកិច្ចសហប្រតិបត្តិការបច្ចេកទេស រវាងស្ថាប័នក្នុងវិស័យសាធារណៈ និងឯកជន ។
**សកម្មភាពទី៥៖**
កៀងគរភាគីពាក់ព័ន្ធនៅក្នុងការអភិវឌ្ឍ និងអនុវត្តការប្រាស្រ័យទាក់ទងគ្នាឱ្យមានប្រសិទ្ធិភាព និងការកសាងផែនការផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ។

## IV. កម្មវិធីតាមវិស័យ និងយុទ្ធសាស្ត្រ សម្រាប់អនុវត្តផែនការសកម្មភាពអាស៊ាន ផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ២០១៦-២០២៥

**អាទិភាពថ្មីរបស់អនុគណៈកម្មការវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា (COST Sub-Committees)**

បន្តតាមការសម្រេចទទួលយកនៃកិច្ចផ្តួចផ្តើមទីក្រុងក្រាប៊ី (KI) ខែធ្នូ ឆ្នាំ២០១០ អនុគណៈកម្មការវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាបានរៀបចំកិច្ចប្រជុំពិសេសមួយនៅថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១១ នៅទីក្រុងហាណូយ ប្រទេសវៀតណាម ដើម្បីប្រមូលគំនិតពិភាក្សាពីលទ្ធភាពក្នុងការបន្តផែនការសកម្មភាពអាស៊ានផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាឆ្នាំ២០០៧ ដល់២០១១ (APAST 2007-2011) ទៅតាមអនុសាសន៍នៃកិច្ចផ្តួចផ្តើមទីក្រុងក្រាប៊ី (KI) ។ អនុគណៈកម្មការក៏បានពិនិត្យឡើងវិញ និងធ្វើការសម្រួលឡើងវិញផងដែរនូវផែនការការងារ (TOR) និងវិស័យដែលចាំបាច់ និងអាទិភាព របស់អនុគណៈកម្មការទាំងនោះ ដើម្បីរក្សានូវភាពពាក់ព័ន្ធរបស់អនុគណៈកម្មការនីមួយៗ ក្នុងការស្ថាបនាសហគមន៍អាស៊ាន ។

**គោលបំណង និងវិស័យជាអាទិភាពរបស់អនុគណៈកម្មការវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា**

| អនុគណៈកម្មការវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ផែនការការងារ/គោលបំណង | វិស័យជាអាទិភាពថ្មី |
|---|---|
| <u>អនុគណៈកម្មការជីវៈបច្ចេកវិទ្យា (SCB)</u><br>អនុគណៈកម្មការ SCB មានភារកិច្ចលើកកំពស់កិច្ចសហប្រតិបត្តិការបច្ចេកវិទ្យាជីវសាស្ត្រក្នុងតំបន់ សម្រាប់ផលិតកម្ម និងធ្វើឱ្យប្រសើរឡើងនូវសម្ភារៈជីវសាស្ត្រ (Bio-materials) សម្រាប់វិស័យកសិកម្ម និងឧស្សាហកម្ម ការប្រើប្រាស់ជីវៈបច្ចេកវិទ្យាសម្រាប់ផលិតកម្ម និងធ្វើប្រសើរឡើងគុណភាពដំណាំ និងសត្វ និងផលិតផលពីដំណាំ និងសត្វទាំងនេះ ការរៀបចំ និងត្រួតពិនិត្យតាមប្រព័ន្ធកុំព្យូទ័រនូវប្រតិកម្មរអាក់ទ័រជីវសាស្ត្រ បច្ចេកវិទ្យាជីវវេជ្ជសាស្ត្រ (វ៉ាក់សាំង)ការបង្ការតាមបែបជីវសាស្ត្រ វិធីសាស្ត្រវែងរករ៉ែតាមបែបជីវសាស្ត្រ និងអភិវឌ្ឍធនធានមនុស្សទៅតាមវិស័យទាំងនេះ ។ ជាមួយគ្នានេះ អនុគណកម្មការ SCB មានភារកិច្ចអភិវឌ្ឍបណ្តាញទំនាក់ទំនងផ្នែកបច្ចេកវិទ្យាជីវសាស្ត្រ និងលើកកម្ពស់ការផ្ទេរបច្ចេកវិទ្យា និងការផ្តល់អាជ្ញាបណ្ណនៃបច្ចេកវិទ្យាទាំងនេះ ព្រមទាំងការចូលរួមប្រតិបត្តិគម្រោង | ១. ជីវៈបច្ចេកវិទ្យាសម្រាប់វិស័យកសិកម្ម (Agri-biotechnology)<br>២. ជីវៈបច្ចេកវិទ្យាថែរក្សាសុខភាព (Healthcare biotechnology)<br>៣. បច្ចេកវិទ្យាដែលកើតមានថ្មី (Emerging technology)<br>មានលក្ខណៈ Science-based innovations<br>៤. ដំណើរការជីៈប្រតិកម្ម (Bio-processing) |

| | |
|---|---|
| ពាក់ព័ន្ធរួមជាមួយវិស័យឯកជន ។<br>**គោលបំណង៖**<br>១. អនុវត្តការស្រាវជ្រាវរួមគ្នាទៅលើប្រធានបទដែលបានកំណត់សម្រាប់គម្រោងនៅក្នុងវិស័យបច្ចេកវិទ្យាជីវសាស្ត្រកសិកម្ម (ដំណាំ សត្វ និងជីវៈចម្រុះ) បច្ចេកវិទ្យាជីវសាស្ត្របរិស្ថាន បច្ចេកវិទ្យាជីវសាស្ត្រឧស្សាហកម្ម និងបច្ចេកវិទ្យាជីវសាស្ត្រវេជ្ជសាស្ត្រ<br>២. ធ្វើការអភិវឌ្ឍធនធានមនុស្ស<br>៣. បង្កើតបណ្ដាញទំនាក់ទំនងព័ត៌មានបច្ចេកវិទ្យាជីវសាស្ត្រអាស៊ាន ។ | |
| **អនុគណៈកម្មការវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាចំណីអាហារ (SCFST)**<br>**គោលបំណងទូទៅ៖**<br>១. លើកកម្ពស់កិច្ចសហប្រតិបត្តិការអាស៊ាន លើវិស័យវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាចំណីអាហារ ដែលឆ្លើយតបទៅនឹងតម្រូវការ និងកម្មវិធីជាតិ និងធ្វើឱ្យប្រសើរឡើងគុណភាពស្ថាប័ន និងធនធានមនុស្ស (ឆ្លើយតបទៅនឹង Thrust 2,4,5,8 នៅក្នុងផែនការសកម្មភាពអាស៊ានផ្នែកវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា (APAST))<br>២. អភិវឌ្ឍវិធានជាយុទ្ធសាស្ត្រដើម្បីកសាងឱ្យរឹងមាំនូវមូលនិធិ សម្រាប់កិច្ចសហប្រតិបត្តិការថ្នាក់តំបន់លើការស្រាវជ្រាវ និងអភិវឌ្ឍ និងសកម្មភាពដ៏ទៃទៀតផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាចំណីអាហារ តាមរយៈការចូលរួមរបស់មជ្ឈមណ្ឌលឧត្តមភាពទៅតាមវិស័យអាទិភាព (ឆ្លើយតបទៅនឹង Thrust 1,3 នៅក្នុងផែនការសកម្មភាព APAST)<br>៣. អនុវត្តសកម្មភាពសហប្រតិបត្តិការក្នុងគម្រោងផ្នែកវិទ្យាសាស្ត្រ ដែលធ្វើឱ្យយន្តការនៃការចូលរួមរបស់ប្រទេសសមាជិកមានប្រសិទ្ធិខ្ពស់ ទៅតាមសមត្ថភាពជាក់ស្តែងជាសក្តានុពល (ឆ្លើយតបទៅនឹង Thrust 2,4 នៅក្នុងផែនការសកម្មភាព APAST)<br>៤. បង្កើតបរិយាកាសឆ្លើយតប សម្រាប់ការធ្វើអន្តរកម្មរបស់អ្នកវិទ្យាសាស្ត្រចំណីអាហារ និងវិស័យឯកជន ដើម្បីបង្កើនលទ្ធផលនៃកិច្ចសហប្រតិបត្តិការផ្នែកវិទ្យាសាស្ត្រ<br>៥. ជម្រុញការធ្វើអន្តរកម្មជាមួយដៃគូអន្តរជាតិ ដើម្បីសម្របសម្រួលកិច្ចសហប្រតិបត្តិការអភិវឌ្ឍវិស័យអាទិភាព នៃសកម្មភាពវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាចំណីអាហារ (ឆ្លើយតបទៅនឹង Thrust7 នៅក្នុងផែនការសកម្មភាព APAST)<br>**គោលបំណងផ្ទាល់៖**<br>១. ពង្រឹងការស្រាវជ្រាវ និងអភិវឌ្ឍន៍រួមគ្នា<br>២. ធ្វើឱ្យប្រសើរឡើងនូវកិច្ចសហការ និងសហប្រតិបត្តិការជាន់ខ្ពស់ក្នុងអាស៊ាន<br>៣. បង្កើតប្រព័ន្ធទិន្នន័យសម្រាប់ការចែករំលែកព័ត៌មាន<br>៤. បង្កើនសមត្ថភាព និងហេដ្ឋារចនាសម្ព័ន្ធ | ១.មុខងារចំណីអាហារ (Functional Food)<br>២.គុណភាព និងសុវត្ថិភាពចំណីអាហារ<br>៣.ផលិតកម្មចំណីអាហារ<br>៤.ការប្រើប្រាស់បច្ចេកវិទ្យាថ្មីដូចជាជីវៈបច្ចេកវិទ្យា និងបច្ចេកវិទ្យាណាណូ ជាដើម |

| | |
|---|---|
| **<u>អនុគណៈកម្មការអភិវឌ្ឍធនធាន និងហេដ្ឋារចនាសម្ព័ន្ធវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា (SCIRD)</u>**<br>អនុគណៈកម្មការ SCIRD មានភារកិច្ចផ្សព្វផ្សាយការសិក្សាគោលនយោបាយវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ធ្វើឱ្យប្រសើរឡើងការគ្រប់គ្រងវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ពង្រីកការបញ្ជ្រាបការយល់ដឹងអំពីការអភិវឌ្ឍវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា នៅក្នុងតំបន់ បង្កើតបណ្តាញទំនាក់ទំនងព័ត៌មានបច្ចេកវិទ្យាអាស៊ាន និងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធសិក្សាសង្គមសម្រាប់អាស៊ាន ។ អនុគណៈកម្មការ SCIRD នឹងបន្តពិនិត្យពិចារណាគម្រោងទាំងឡាយ ដែលអនុគណៈកម្មការទាំង៨ ផ្សេងទៀតពុំអាចមើលដល់ ។<br>គោលបំណង៖<br>១. អភិវឌ្ឍទស្សនវិស័យបច្ចេកវិទ្យា និងដំណើរការធ្វើផែនការ<br>២. ផ្សព្វផ្សាយកិច្ចសហប្រតិបត្តិការផ្នែកសិក្សាគោលនយោបាយ និងការគ្រប់គ្រងការងារវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា<br>៣. អភិវឌ្ឍបណ្តាញទំនាក់ទំនងព័ត៌មាន និងបច្ចេកវិទ្យាអាស៊ាន<br>៤. អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ដូចជាប្រព័ន្ធសម្រាប់ការសិក្សាជាក់ស្តែង នៅក្នុងអាស៊ាន ។ | ១.ការសិក្សាអំពីវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា<br>២.ការគ្រប់គ្រងការងារវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា និងការផ្សព្វផ្សាយព័ត៌មាន<br>៣.បណ្តាញទំនាក់ទំនងព័ត៌មានវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាអាស៊ាន (ASTNET)<br>៤.បណ្តុះការយល់ដឹងផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍<br>៥.ផ្តោតទៅលើផ្នែកមូលដ្ឋាននៃពីរ៉ាមីដ<br>៦.ការធ្វើនវានុវត្តន៍ផ្តោតលើយុវវ័យ<br>៧.វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍សម្រាប់សង្គមបៃតង (Green Society)<br>៨.វេទិកាដៃគូសាធារណៈ និងឯកជន |
| **<u>អនុគណៈកម្មការឧតុនិយម និងភូគព្ភសាស្ត្រ (SCMG)</u>**<br>អនុគណៈកម្មការ SCMG មានភារកិច្ចពង្រីកសមត្ថភាពសេវាកម្មផ្នែកឧតុនិយម និងភូគព្ភសាស្ត្រ ដើម្បីការពារជីវិត និងទ្រព្យសម្បត្តិរបស់ប្រជាពលរដ្ឋនៅក្នុងតំបន់ និងសម្រាប់វិស័យអនុវត្តន៍ (ដូចជាអាកាសចរណ៍ កសិកម្ម នាវាចរណ៍ ទេសចរណ៍) ដើម្បីធ្វើឱ្យប្រសើរឡើងនូវសេវាកម្មការព្យាករណ៍ និងប្រព័ន្ធផ្តល់ព័ត៌មានជាមុនអំពីហានិភ័យដែលអាចកើតមាន (Early Warning System) ពាក់ព័ន្ធនឹងការបន្ធូរបន្ថយគ្រោះធម្មជាតិដែលកើតមានឡើងដោយសារបាតុភូតឧតុនិយម និងភូគព្ភសាស្ត្រ និងដើម្បីបង្កើត ឬពង្រីកមជ្ឈមណ្ឌល ដើម្បីគាំទ្រដល់តម្រូវការរបស់ប្រទេសសមាជិកអាស៊ានក្នុងវិស័យឧតុនិយម ផ្កាយរណបឧតុនិយម អាកាសធាតុសាស្ត្រ ការរញ្ជួយផែនដី បន្ទុះភ្នំភ្លើង និងការងារបរិស្ថានទាក់ទងនឹងឧតុនិយម និងភូគព្ភសាស្ត្រ។ ដើម្បីគាំទ្រទៅដល់តម្រូវការទាំងនេះអនុគណៈកម្មការនឹងសម្របសម្រួលបណ្តាញទំនាក់ទំនងរបស់ប្រព័ន្ធឧតុនិយម ភូគព្ភសាស្ត្រ ការរញ្ជួយដី និងបន្ទុះភ្នំភ្លើង រួមបញ្ចូលទាំងការធ្វើស្តង់ដារូបណីយកម្មនៃការវាស់វែងផ្នែកភូគព្ភសាស្ត្រ និងរញ្ជួយដី ។ លើសពីនេះទៀតនឹងមានការស្រាវជ្រាវលើផ្នែកឧតុនិយម និងភូគព្ភសាស្ត្រ រួមមានការព្យាករណ៍អាកាសធាតុ ឧតុនិយមខ្យល់មូសុង ជីវចម្រុះក្នុង | ១.ភាពមិនស្ថិតស្ថេរ និងការប្រែប្រួលអាកាសធាតុ<br>២.បញ្ហាឧតុនិយមពាក់ព័ន្ធនឹងជលសាស្ត្រ និងភូគព្ភសាស្ត្រ<br>៣.ឧតុនិយមពីស្ថានភាពក្នុងសមុទ្រ និងសាគរសាស្ត្រ<br>៤.បញ្ហាបរិស្ថានថ្នាក់តំបន់ និងឧតុនិយមបរិស្ថាន<br>៥.ការកសាងសមត្ថភាពថ្នាក់ជាតិអំពីសេវាកម្មឧតុនិយម និងភូគព្ភសាស្ត្រ |

សមុទ្រ និងការបំពុលខ្យល់ ការព្យាករណ៍ពីការរញ្ជួយផែនដី និងការកំណត់ និងវាយតម្លៃតំបន់មានហានិភ័យ ។ ដើម្បីគាំទ្រដល់សកម្មភាពទាំងនេះ នឹងមានការអនុវត្តកម្មវិធីបណ្តុះបណ្តាល និងផ្លាស់ប្តូរចំណេះដឹងជាច្រើន ។

**គោលបំណង៖**

១. ផ្នែកអាកាសធាតុ ការប្រែប្រួលអាកាសធាតុ និងភាពផ្លាស់ប្តូរអាកាសធាតុ៖

ក)ពង្រឹងសមត្ថភាពមជ្ឈមណ្ឌលឧតុនិយម (ASEAN Specialized Meteorological Centre-ASMC) របស់អាស៊ាន និងរបស់ប្រទេសជាសមាជិក

ខ)ជម្រុញការកសាងសមត្ថភាពនៅក្នុងប្រទេសសមាជិកអាស៊ាន នៅផ្នែកសេវាកម្មព័ត៌មានបរិស្ថាន និងការព្យាករណ៍ ។

២. ការងារឧតុនិយម និងភូគព្ភសាស្ត្រ៖

ក)បន្តពង្រឹងការសម្របសម្រួលក្នុងចំណោមប្រទេសមាជិក ក្នុងការតាមដានអង្កេតពីអាកាសធាតុ និងការផ្លាស់ប្តូរទិន្នន័យ និងផលិតផល

ខ)លើកកម្ពស់ការផ្លាស់ប្តូរព័ត៌មានអំពីការរញ្ជួយដី បន្ទុះភ្នំភ្លើង និងការចែករំលែកព័ត៌មានឱ្យបានទាន់ពេលអំពីទិន្នន័យនៃការរញ្ជួយដី ។

៣.ការងារបរិស្ថានថ្នាក់តំបន់ទាក់ទងនឹងឧតុនិយម

ក)ពង្រឹងសមត្ថភាពសេវាកម្មរបស់អាស៊ានផ្នែកឧតុនិយមជាតិ ដើម្បីតាមដាន និងវាយតម្លៃ និងគម្រូជីវៈចម្រុះសមុទ្រ និងការបំពុលខ្យល់ ជាពិសេសហេតុការណ៍រំខានទាំងឡាយ

ខ)ពង្រឹងសមត្ថភាពអាស៊ាននៅក្នុងវិស័យឧតុនិយមផ្កាយរណប និងការវាស់វែងពីគ្រោះថ្នាក់ក្នុងបរិយាកាស

គ)ពង្រឹង និងពង្រីកការចូលរួមរបស់អាស៊ាននៅក្នុងសកម្មភាពពាក់ព័ន្ធនៃ WMO-Global Atmosphere Watch (GAW) ។

៤) ការកសាងសមត្ថភាពជាតិផ្នែកសេវាកម្មឧតុនិយម និងភូគព្ភសាស្ត្រ

ក)ជួយដល់ប្រទេសសមាជិកអាស៊ាន ក្នុងការជម្រុញប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន (Information Technology) និងដើម្បីឱ្យមានគ្រប់គ្រាន់នូវធនធាន និងមធ្យោបាយ

ខ)ជម្រុញការប្រើប្រាស់ IT សម្រាប់ការផ្លាស់ប្តូរឱ្យបានឆាប់នូវការវិភាគលទ្ធផល (Data products) និងការផ្សព្វផ្សាយដល់សាធារណជន អំពីការព្យាករណ៍ និងការព្រមានអំពីស្ថានភាពអាកាសធាតុ និងការរញ្ជួយដី ។

គ)ជួយដល់សេវាកម្មឧតុនិយមជាតិរបស់ប្រទេសសមាជិក ដើម្បីអភិវឌ្ឍសេវាកម្មចំគោលដៅអតិថិជន (Client-oriented services)

៥)ការស្រាវជ្រាវ និងអភិវឌ្ឍន៍

អនុគណៈកម្មការនឹងជួយពង្រឹងផ្នែកឧតុនិយម និងភូគព្ភសាស្ត្រនៅក្នុងអាស៊ានតាមរយៈការផ្សព្វផ្សាយអំពីការសិក្សា និងសម្របសម្រួលការចែករំលែកចំណេះដឹង ជំនាញ សម្ភារៈ និងការបោះពុម្ពផ្សាយ សម្រាប់វិស័យ Weather modification (សកម្មភាពស្វែងរកវិធីសាស្ត្រដើម្បីកាត់បន្ថយផលប៉ះពាល់ដល់

| | |
|---|---|
| និងជាទូទៅដើម្បីស្វែងរកប្រភពទឹកភ្លៀង ជាប្រភពផ្គត់ផ្គង់ទឹក) ការសិក្សា និងការព្យាករណ៍ពីអាកាសធាតុមូសុងក្នុងតំបន់ ការប្រែប្រួលអាកាសធាតុក្នុងតំបន់ ដូចជាការជន់ឡើងនៃកម្ពស់ទឹកសមុទ្រ និងផលប៉ះពាល់ ENSO និងឥទ្ធិពលរបស់វានៅក្នុងតំបន់ ការបាត់បង់ជីវៈចម្រុះក្នុងទឹក និងការបំពុលខ្យល់ និងគុណវិបត្តិនៃការសិក្សាពីបាតុភូតរញ្ជួយដីពីបុរាណ និងការរញ្ជួយដី ។ | |
| **<u>អនុគណៈកម្មការមីក្រូអេឡិចត្រូនិក និងបច្ចេកវិទ្យាព័ត៌មាន (SCMIT)</u>**<br>អនុគណៈកម្មការ SCMIT មានភារកិច្ចអភិវឌ្ឍ និងពង្រីកសមត្ថភាពផ្នែកមីក្រូអេឡិចត្រូនិក និងបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានរបស់ប្រទេសជាសមាជិកអាស៊ាន និងវិស័យពាក់ព័ន្ធរបស់បច្ចេកវិទ្យានេះតាំងពីអ្នកផលិត រហូតដល់អ្នកប្រើប្រាស់ ។ អនុគណៈកម្មការនេះនឹងអនុវត្តគម្រោងស្រាវជ្រាវ អភិវឌ្ឍន៍បច្ចេកវិទ្យា គម្រោងកសាងសមត្ថភាព និងគម្រោងអនុវត្តសាកល្បង នៅក្នុងផ្នែកមីក្រូអេឡិចត្រូនិក បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ទៅតាមវិធានគោលនយោបាយ (Strategic Thrusts)<br>**គោលបំណង៖**<br>១.អនុវត្តការកសាងសមត្ថភាពសម្រាប់ប្រទេសសមាជិកអាស៊ាន ដែលមានការអភិវឌ្ឍតិចតួច<br>២.ផ្សព្វផ្សាយ និងអនុវត្តការផ្ទេរការស្រាវជ្រាវ និងអភិវឌ្ឍបច្ចេកវិទ្យា (R&D Technology Transfer) ក្នុងផ្នែកមីក្រូអេឡិចត្រូនិក បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន<br>៣.ជម្រុញ និងពង្រឹងសកម្មភាពខាងក្នុងអាស៊ាន នៅក្នុងវិស័យអាទិភាព<br>៤.ពង្រីកវិសាលភាពបណ្ដាញព័ត៌មាន ឬប្រព័ន្ធទិន្នន័យ សម្រាប់ចែករំលែក និងផ្សព្វផ្សាយទាំងក្នុង និងក្រៅអាស៊ាន<br>៥.ពង្រឹងសមត្ថភាពស្ថាប័ន និងមជ្ឈមណ្ឌលឧត្តមភាព ។ | ១.រៀបចំប្លង់មីក្រូអេឡិចត្រូនិក និងគមនាគមន៍ និងព័ត៌មាន<br>២. អនុវត្តការផ្សព្វផ្សាយ ជាសាធារណៈ<br>៣.ការសិក្សាតាមប្រព័ន្ធអេឡិចត្រូនិកពីចម្ងាយ (E-learning)<br>៤.ប្រព័ន្ធ Embedded Systems<br>៥.គ្រឿងយន្ត Robotics<br>៦.ប្រព័ន្ធ ឬកម្មវិធី Open source systems<br>៧.ប្រព័ន្ធ Image processing and vision systems<br>៨.ប្រព័ន្ធសន្តិសុខ និងស្រង់ព័ត៌មាន (Security and surveillance systems)<br>៩.ការប្រើប្រាស់កុំព្យូទ័រល្បឿនលឿន ខ. Cloud computing and grid technology |
| **<u>អនុគណៈកម្មការវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាលំហរសមុទ្រ (SCMSAT)</u>**<br>អនុគណៈកម្មការSCMSAT មានភារកិច្ចលើកកម្ពស់ការអភិវឌ្ឍប្រកបដោយចីរភាពនៃភាវៈរស់ក្នុងសមុទ្រ និងធនធានដែលគ្មានជីវិត ហើយបង្កើននូវសក្ដានុពលនៃធនធាននេះ ដើម្បីបំពេញតាមសេចក្ដីត្រូវការរបស់អាស៊ាន ។ អនុគណៈកម្មការនេះក៏មានភារកិច្ចផងដែរ ក្នុងការបង្កើនបរិមាណអ្នកជំនាញខាងផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាលំហរសមុទ្រ ។ | ១.បច្ចេកវិទ្យាជីវសាស្ត្រជលជាតិ និងការបណ្ដុះពពួកជលជាតិ (Aquatic bio-technology and aquaculture)<br>២.ការបំពុលដោយពពួកជលជាតិ ដែលអាចឆ្លងប្រទេស (សមុទ្រ)<br>៣.ការគ្រប់គ្រងហានិភ័យ និងការបន្សាំខ្លួនទៅនឹងការប្រែប្រួលអាកាសធាតុ<br>៤.ថាមពលករកើតឡើងវិញ |

| | |
|---|---|
| | (ឧ.ថាមពលដែលបានពីពពួកស្លែតូចៗ) |
| <u>**អនុគណៈកម្មការសម្ភារៈវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា (SCMST)**</u><br>អនុគណៈកម្មការ SCMST មានភារកិច្ចអភិវឌ្ឍសារធាតុ ឬសម្ភារៈថ្មី សម្រាប់ចេរភាពបរិស្ថាន ធ្វើការប្រើប្រាស់ទាំងវត្ថុធាតុដើមក្នុងស្រុក និងសំណល់សម្ភារៈ និងអភិវឌ្ឍការច្នៃប្រឌិត-បង្កើតថ្មីនូវបច្ចេកវិទ្យាអនាគតដែលមានការរំពឹងទុក តាមរយៈការភ្ជាប់បណ្តាញទំនាក់ទំនង និងការកសាងធនធានមនុស្ស ។<br>អនុគណៈកម្មការនេះនឹងធ្វើកិច្ចសហប្រតិបត្តិការស្រាវជ្រាវ និងអភិវឌ្ឍន៍ ដែលមានរូបក្នុងធម្មជាតិ សម្រាប់ប្រទេសមាជិកអាស៊ាន ក្នុងវិស័យសម្ភារៈសម្រាប់ការគ្រប់គ្រងបរិស្ថាន សារធាតុ ឬសម្ភារៈដែលសមប្រកបនឹងបរិស្ថានដែលមានប្រភពក្នុងប្រទេសសមាជិកអាស៊ាន សម្រាប់ការប្រើប្រាស់បច្ចេកវិទ្យាខ្ពស់ដោយប្រើប្រាស់ប្រភពដែលមានក្នុងស្រុក និងសារធាតុ ឬសម្ភារៈដែលអាចរលាយក្នុងដី ឬអាចកែច្នៃឡើងវិញបាន ។ អនុគណៈកម្មការនេះ នឹងអភិវឌ្ឍបណ្តាញព័ត៌មានបច្ចេកវិទ្យា ក៏ដូចជាអភិវឌ្ឍយន្តការប្រឹក្សាយោបល់បច្ចេកទេស សម្រាប់ក្តីបារម្ភរបស់ឧស្សាហកម្ម ការផ្ទេរបច្ចេកវិទ្យា និងការចែករំលែក ផ្លាស់ប្តូរធនធានមនុស្សសម្រាប់ការងារស្រាវជ្រាវ និងអភិវឌ្ឍ ។<br>គោលបំណងសំខាន់៖<br>១.អនុវត្តកិច្ចសហប្រតិបត្តិការស្រាវជ្រាវ និងអភិវឌ្ឍរបស់ប្រទេសសមាជិកអាស៊ាន អំពីសារធាតុថ្មី ឬសារធាតុច្នៃប្រឌិត-បង្កើតថ្មី សម្រាប់ការប្រើប្រាស់បច្ចេកវិទ្យាខ្ពស់<br>២.អភិវឌ្ឍ/បង្កើតសារធាតុ ឬសម្ភារៈដែលសមប្រកបនឹងបរិស្ថាន<br>៣.កសាងបណ្តាញទំនាក់ទំនងសម្រាប់ផ្លាស់ប្តូរព័ត៌មាន<br>៤.លើកកម្ពស់កម្មវិធីការអភិវឌ្ឍធនធានមនុស្ស តាមរយៈការបណ្តុះបណ្តាល សិក្ខាសាលា និងកិច្ចប្រជុំ<br>៥.ផ្សព្វផ្សាយពីការប្រើប្រាស់មធ្យោបាយឱ្យមានប្រយោជន៍ខ្ពស់ តាមរយៈការផ្លាស់ប្តូរអ្នកវិទ្យាសាស្ត្រ និងនិស្សិត | ១.សារធាតុ/សម្ភារៈសម្រាប់ណាណូបច្ចេកវិទ្យា និងសារធាតុ/ សម្ភារៈដែលមានមុខងារច្រើនយ៉ាង<br>២.សារធាតុសម្ភារៈដែលមានជីវៈ/ សមាសធាតុ សម្រាប់សម្ភារៈជីវៈសុខាភិបាល |
| <u>**អនុគណៈកម្មការសិក្សាស្រាវជ្រាវថាមពលប្រកបដោយចីរភាព (SCSER)**</u><br>អនុគណៈកម្មការ SCSER មានភារកិច្ចអភិវឌ្ឍ និងពង្រឹងសមត្ថភាពរបស់ប្រទេសសមាជិកអាស៊ាន ក្នុងផ្នែកបច្ចេកវិទ្យាប្រើប្រាស់ឧស្ម័នធម្មជាតិ បច្ចេកវិទ្យាជីវៈម៉ាស់ និងជីវៈឧស្ម័ន បច្ចេកវិទ្យាស្អាតធ្យូងថ្ម (Clean coal technology) ថាមពលពន្លឺព្រះអាទិត្យ ថាមពលខ្យល់ វារីអគ្គិសនីខ្នាតតូច និងបច្ចេកវិទ្យាប្រសិទ្ធិភាពថាមពល អនុគណៈកម្មការនេះ អនុវត្តការស្រាវជ្រាវ អភិវឌ្ឍ និងដំណើរការគម្រោងសាកល្បង នោះក្នុងការគ្រប់គ្រងថាមពល និងវិស័យអាទិភាពខាងលើ ។<br>គោលបំណងសំខាន់៖<br>១.អនុវត្តការផ្ទេរបច្ចេកវិទ្យា R&D និងការធ្វើពាណិជ្ជកម្មប្រភពថាមពលមិនធម្មតា និងថាមពលជំនួស ដូចជាបច្ចេកវិទ្យាប្រើប្រាស់ឧស្ម័នធម្មជាតិ បច្ចេកវិទ្យាជីវៈ | ១.ថាមពលថ្មី ថាមពលកកើតឡើងវិញ ឬថាមពលជំនួស ដូចជាថាមពលជីវៈម៉ាស់ ថាមពលកំដៅក្នុងផែនដី (Geothermal energy) ថាមពលពន្លឺព្រះអាទិត្យ និងថាមពលអគ្គិសនីដើរដោយប្រតិកម្មគីមី<br>២.ថាមស្អាត និងបច្ចេកវិទ្យា |

| | |
|---|---|
| ម៉ាស់ និងជីវៈឧស្ម័ន បច្ចេកវិទ្យាស្អាតធ្យូងថ្ម (Clean coal technology) ថាមពលពន្លឺ ព្រះអាទិត្យ ថាមពលខ្យល់ វារីអគ្គិសនីខ្នាតតូច និងបច្ចេកវិទ្យាប្រសិទ្ធិភាពថាមពល<br>២.ជម្រុញ និងពង្រឹងសកម្មភាពខាងក្នុងអាស៊ានក្នុងវិស័យជាអាទិភាពទាំងឡាយ<br>៣.ពង្រឹងបណ្តាញ ឬប្រព័ន្ធទិន្នន័យព័ត៌មាន សម្រាប់ចែករំលែក ឬផ្លាស់ប្តូរព័ត៌មាន នៅក្នុង ឬក្រៅប្រទេសអាស៊ាន<br>៤.ពង្រឹងស្ថាប័ន និងមជ្ឈមណ្ឌលឧត្តមភាព ។ | បរិស្ថាន ដូចជាឧស្ម័នស្អាត ឧស្ម័នធម្មជាតិ និងឧស្ម័នអ៊ីដ្រូសែន<br>៣.បច្ចេកវិទ្យាថាមពលឧស្សាហកម្ម ដូចជាដំណើរការថាមពល Cogeneration និងការគ្រប់គ្រងថាមពលអគារ ។ |
| <u>**អនុគណៈកម្មការបច្ចេកវិទ្យាលំហអាកាស និងការអនុវត្ត (SCOSA)**</u><br>គោលបំណងសំខាន់របស់អនុគណៈកម្មការ SCOSA គឺកំណត់ក្របខណ្ឌការងារសម្រាប់ពង្រឹងកិច្ចសហប្រតិបត្តិការបច្ចេកវិទ្យាលំហអាកាស និងការអនុវត្តបច្ចេកវិទ្យានេះ និងដើម្បីដំណើរការគម្រោង និងកម្មវិធី ឆ្ពោះទៅរកការដំណើរការបច្ចេកវិទ្យាទាំងនេះ សម្រាប់កិច្ចអភិវឌ្ឍន៍ប្រកបដោយចីរភាព នៅក្នុងតំបន់អាស៊ាន ។ សម្រេចបានគោលបំណងនេះ គណៈកម្មការ SCOSA ត្រូវ<br>១.កំណត់ និងសម្របសម្រួលកម្មវិធី និងគម្រោងកិច្ចសហការ និងកិច្ចសហប្រតិបត្តិការ ជាពិសេសគម្រោង Remote Sensing ឧតុនិយមតាមផ្កាយរណប គមនាគមន៍ និងការប្រើប្រាស់បច្ចេកវិទ្យាផ្កាយរណប សម្រាប់ការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន និងការធ្វើផែនការអភិវឌ្ឍ<br>២.ពិនិត្យមើលឡើងវិញនូវស្ថានភាព និងសមត្ថភាពបច្ចេកវិទ្យាលំហអាកាស នៅក្នុងតំបន់ និងធ្វើការផ្សព្វផ្សាយពីបច្ចេកវិទ្យានេះសម្រាប់គ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន<br>៣.ផ្តល់អនុសាសន៍រៀបចំយន្តការដើម្បីឱ្យមានការចូលរួមពីខាងរដ្ឋាភិបាល ឧស្សាហកម្ម និងវិទ្យាល័យ ក្នុងការផ្សព្វផ្សាយ និងធ្វើកិច្ចសហប្រតិបត្តិការថ្នាក់តំបន់ ប្រកបដោយចីរភាព នៅក្នុងផ្នែកបច្ចេកវិទ្យាលំហអាកាស និងដាក់វាឱ្យដំណើរការ<br>៤.ធ្វើការផ្លាស់ប្តូរព័ត៌មានអំពីកម្មវិធី និងគោលនយោបាយជាតិ និងការធ្វើផែនការនៅក្នុងផ្នែកទាំងអស់នៃបច្ចេកវិទ្យាលំហអាកាស និងការប្រើប្រាស់វា នៅក្នុងតំបន់អាស៊ាន ។<br>៥.សម្របសម្រួល និងពន្លឿនការផ្ទេរបច្ចេកវិទ្យាលំហអាកាស និងការប្រើប្រាស់បច្ចេកវិទ្យានេះ ទៅប្រទេសក្នុងតំបន់អាស៊ាន<br>៦.ធ្វើប្រសើរឡើងនូវសកម្មភាព និងគម្រោងកិច្ចសហប្រតិបត្តិការជាមួយស្ថាប័នអន្តរជាតិដែលពាក់ព័ន្ធ អំពីបច្ចេកវិទ្យាក្នុងលំហអាកាស និងការប្រើប្រាស់វា<br>៧.ផ្តល់ការប្រឹក្សាដល់គណៈកម្មាធិការអាស៊ានផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា អំពីបញ្ហាពាក់ព័ន្ធនឹងបច្ចេកវិទ្យាក្នុងលំហអាកាស និងការប្រើប្រាស់វា<br>៨.ជួយដល់ការគាំទ្រផ្នែកហិរញ្ញវត្ថុ និងស្វែងរកប្រភពថវិកាសម្រាប់សកម្មភាព និងគម្រោងរបស់អាស៊ាន ដែលទាក់ទងនឹងបច្ចេកវិទ្យាក្នុងលំហអាកាស និងការប្រើប្រាស់វា ។ | ១.ព័ត៌មានភូមិសាស្ត្រ<br>២.ការប្រើប្រាស់បច្ចេកវិទ្យាផ្កាយរណប ដូចជាការតាមដានត្រួតពិនិត្យគ្រោះធម្មជាតិ និងបរិស្ថាន<br>៣.ផ្កាយរណបខ្នាតមីក្រូ ខ្នាតតូច Sensors និងឧបករណ៍លើដី |

កម្មវិធី Flagship Programmes ទាំង៦ នៃផែនការសកម្មភាពអាស៊ានផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាឆ្នាំ២០០៧-២០១១ (APAST 2007-2011) (ដែលបានពន្យារបន្តរហូតដល់ឆ្នាំ២០១៥) ស្ថិតនៅក្នុង Thematic Trucks ទាំង៨ នៃកិច្ចផ្តួចផ្តើមទីក្រុងក្រាប៊ី (KI) ។ អនុគណៈកម្មការនីមួយៗបានទទួលស្គាល់ថាវិស័យជាអាទិភាពទាំងអស់ខាងលើ នឹងបន្តចូលរួមទៅតាមតម្រូវការ និងការអភិវឌ្ឍថ្មីរបស់អាស៊ាន និងសហគមន៍អន្តរជាតិ ។ អនុគណៈកម្មការទាំងនេះ ត្រូវបានរំពឹងទុកថានឹងកំណត់នូវកម្មវិធីការងាររបស់ខ្លួន ដើម្បីគាំទ្រដល់ផែនការសកម្មភាពអាស៊ានផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ឆ្នាំ២០១៦-២០២៥ (APASTI 2016-2025) ។ កម្មវិធីការងារផ្ទាល់ខ្លួនរបស់អនុគណៈកម្មការនីមួយៗ ត្រូវបង្រួមចូលគ្នា និងបង្កើតបានជាផែនការអនុវត្តរបស់ផែនការសកម្មភាព APASTI ។

## V. ក្របខណ្ឌការងារគ្រប់គ្រងរបស់គណៈកម្មាធិការអាស៊ានផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា

គោលនយោបាយសម្រាប់កិច្ចសហប្រតិបត្តិការអាស៊ាន ផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ត្រូវបានដាក់ចេញដោយកិច្ចប្រជុំប្រចាំឆ្នាំរបស់រដ្ឋមន្ត្រីវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាអាស៊ាន (AMMST) ។ ចំណែកគណៈកម្មាធិការអាស៊ានផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា (COST) មានភារកិច្ចៈ

(i) កំណត់ទិសដៅ សម្របសម្រួលសកម្មភាពអនុគណៈកម្មការ (Sub-Committees) និងអង្គភាពក្រោមឱវាទខ្លួន

(ii) ធ្វើការបញ្ជ្រាបការយល់ដឹងជាសាធារណៈអំពីសកម្មភាពថ្នាក់តំបន់ផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា និងការរួមវិភាគទាន COST, Sub-Committees និងអង្គភាពផ្សេងទៀតរបស់ COST ទៅក្នុងការអភិវឌ្ឍសេដ្ឋកិច្ច

(iii) ធ្វើការពិនិត្យឡើងវិញនូវវឌ្ឍនភាពនៃកិច្ចសហប្រតិបត្តិការ រួមទាំងវឌ្ឍនភាពនៃនៃទំនាក់ទំនងជាមួយដៃគូរចរចារបស់អាស៊ាន និងកិច្ចសហប្រតិបត្តិការខាងក្រៅផ្សេងទៀត ។

<u>**បច្ចុប្បន្នភាពនៃរចនាសម្ព័ន្ធកិច្ចសហប្រតិបត្តិការអាស៊ានផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា**</u>

Fig. 1 - Existing Structure of ASEAN cooperation in S&T




អនុគណៈកម្មការ (Sub-Committee) នីមួយៗត្រូវបានបង្កើតឡើងដើម្បីមើលខុសត្រូវការគ្រប់គ្រង ការសម្របសម្រួល ការវាយតម្លៃ និងអនុវត្តកម្មវិធី និងគម្រោងថ្នាក់តំបន់ ។ អនុគណៈកម្មការទាំងនេះ ត្រូវបានរំពឹងថានឹងវាយតម្លៃប្រសិទ្ធភាព និងលទ្ធផលគម្រោងទាំងឡាយរបស់គេ នៅក្នុងការពង្រឹងសមត្ថភាពវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាក្នុងតំបន់ ។ ចំណែកក្រុមប្រឹក្សាផ្តល់យោបល់ (Advisory Bodies) ក៏ត្រូវបានបង្កើតឡើងផងដែរ ដើម្បីផ្តល់អនុសាសន៍គោលនយោបាយដល់ COST អំពីបញ្ហាទាក់ទងនឹងការអនុវត្តផែនការសកម្មភាពអាស៊ានផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា (APAST) ក៏ដូចជាការគ្រប់គ្រងមូលនិធិវិទ្យាសាស្ត្រអាស៊ាន ។

អនុគណៈកម្មការ និងក្រុមប្រឹក្សាយោបល់ទាំងនោះរួមមានៈ
-អនុគណៈកម្មការជីវៈបច្ចេកវិទ្យា (Sub-Committee on Biotechnology-SCB)
-អនុគណៈកម្មការវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាចំណីអាហារ (Sub-Committee on Food Science and Technology-SCFST)
-អនុគណៈកម្មការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងធនធានវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា (Sub-Committee on S&T Infrastructure and Resource Development-SCIRD)
-អនុគណៈកម្មការឧតុនិយម និងភូគព្ភសាស្ត្រ (Sub-Committee on Meteorology and Geophysics-SCMG)
-អនុគណៈកម្មការមីក្រូអេឡិចត្រូនិក និងបច្ចេកវិទ្យាព័ត៌មាន (Sub-Committee on Microelectronic and Information Technology)
-អនុគណៈកម្មការវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាលំហរសមុទ្រ (Sub-Committee on Marine Science and Technology-SCMSAT)
-អនុគណៈកម្មការវិទ្យាសាស្ត្រសម្ភារៈ និងបច្ចេកវិទ្យា (Sub-Committee on Material Science and Technology-SCMST)
-អនុគណៈកម្មការស្រាវជ្រាវថេរភាពថាមពល(Sub-Committee on Sustainable Energy Research-SCSER)
-អនុគណៈកម្មការបច្ចេកវិទ្យាលំហរអាកាស និងអនុវត្តន៍ (Sub-Committee on Space Technology and Applications-SCOSA)
-ក្រុមប្រឹក្សាយោបល់លើមូលនិធិវិទ្យាសាស្ត្រអាស៊ាន (Advisory Body of the ASEAN Science Fund-ABASF)
-ក្រុមប្រឹក្សាយោបល់លើផែនការសកម្មភាពអាស៊ានផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា (Advisory Body on the ASEAN Plan of Action on Science and Technology-ABAPAST) ។

លើសពីនេះទៀត អនុគណៈកម្មការខ្លះបានបង្កើតកម្លាំងជំនាញ (Task Force) ក្រុមការងារ (Working Group) និងក្រុមជំនាញការ (Expert Group) ដើម្បីធ្វើការងារលើវិស័យជាក់លាក់ដែលពាក់ព័ន្ធ ។ ជាមួយគ្នានេះ កិច្ចសហប្រតិបត្តិការជាមួយដៃគូចរចារបស់អាស៊ានក៏ត្រូវបានកំណត់ឡើង តាមរយៈការបង្កើតគណៈកម្មការរួម (Joint Committees) ក្រុមការងារ (Working Groups) និងវេទិការផ្សេងទៀត (Related Platforms) ដូចជាៈ
-កម្លាំងជំនាញបច្ចេកទេសដែលផ្ដល់ដំណឹងជាមុនអំពីព្យុះបែបស៊ូណាមិ (Technical Task Force on Tsunami Warning - TTF-TW) ស្ថិតក្រោមអនុគណៈកម្មការ SCMG
-ក្រុមការងារបច្ចេកទេសផ្នែកម៉ាស៊ីនថាមពលនុយក្លេអែរ (Technical Working Group on Nuclear Power Plant – TWG-NPP) ដែលស្ថិតក្រោមអនុគណៈកម្មការ SCSER
-ក្រុមជំនាញការផ្នែកមាត្រាសាស្ត្រ (Experts Group on Metrology – EMG) ស្ថិតក្រោមអនុគណៈកម្មការ SCIRD
-គណៈកម្មការរួមអាស៊ាន-ចិនផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា (ASEAN-China Joint Science and Technology Committee - ASEAN-China JSTC)
-ដៃគូចរចារអាស៊ាន-សហគមន៍អឺរ៉ុបផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា (ASEAN-EU Dialogue on Science and Technology - ASEAN-EU DST)
-ក្រុមការងារអាស៊ាន-ឥណ្ឌាផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា (ASEAN-India Working Group on Science and Technology - ASEAN-India WGST)

-គណៈកម្មការសហប្រតិបត្តិការអាស៊ាន-ជប៉ុនផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា (ASEAN-Japan Cooperation Committee on Science and Technology - ASEAN-Japan CCST)

-គណៈកម្មការរួមអាស៊ាន-កូរ៉េផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា(ASEAN-ROK Joint Science and Technology Committee - ASEAN-ROK JSTC)

-ក្រុមការងារអាស៊ាន-រុស្ស៊ីផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា (ASEAN-Russia Working Group on Science and Technology - ASEAN-Russia WGST)

-ទីប្រឹក្សាយោបល់អាស៊ាន-អាមេរិក (ASEAN-US Consultation on Science and Technology - ASEAN-US CST)

-គណៈកម្មាធិការវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាអាស៊ានបូកបី (ASEAN COST Plus China, Japan and ROK - ASEAN COST+3) ។

ការធ្វើកំណែទម្រង់រចនាសម្ព័ន្ធគណៈកម្មាធិការអាស៊ានផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា និងអង្គភាពទាំងអស់ដែលស្ថិតក្រោមគណៈកម្មាធិការនេះ បានក្លាយជាប្រធានបទមួយដែលត្រូវបានលើកឡើងនៅក្នុងកិច្ចប្រជុំកម្មាធិការអាស៊ានផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា និងកិច្ចប្រជុំរដ្ឋមន្ត្រីវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាអាស៊ានជាបន្តបន្ទាប់ ។ កិច្ចប្រជុំក្រៅផ្លូវការលើកទី៨ របស់រដ្ឋមន្ត្រីវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាអាស៊ាន (IMMST-8) នៅទីក្រុង Bogor ប្រទេសឥណ្ឌូណេស៊ី បានគាំទ្រអនុសាសន៍ក្រុមការងារជាន់ខ្ពស់ (High-Level Task Force-HLTF) ថាតើត្រូវពង្រឹងលេខាធិការដ្ឋានអាស៊ានយ៉ាងដូចម្ដេច និងត្រូវពិនិត្យមើលឡើងវិញ យ៉ាងដូចម្ដេចនូវស្ថាប័ន ឬអង្គភាពរបស់គណៈកម្មាធិការអាស៊ានផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ។ នៅពេលនោះ ថ្នាក់រដ្ឋមន្ត្រីបានឯកភាពថាត្រូវកំណត់ឱ្យច្បាស់នៅក្នុងផែនការសកម្មភាពអាស៊ានផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា និង នវានុវត្តន៍ (APASTI) អំពីយន្តការសមស្របមួយនៅក្នុងការធ្វើកំណែទម្រង់គណៈកម្មាធិការអាស៊ានផ្នែក វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា និងស្ថាប័ន ឬអង្គភាពរបស់គណៈកម្មាធិការនេះ ។ ការធ្វើកំណែទម្រង់គណៈកម្មាធិការអាស៊ាន COST នេះ អាចតាមរយៈការរំលាយ ឬប្របាច់បញ្ចូលគ្នា នូវអង្គភាពរបស់ COST រួមទាំងការកំណត់ឡើងវិញនូវ TOR និងដំណើរការនៃការជ្រើសរើសប្រធាន COST និងប្រធានអនុគណៈកម្មការ ឬក្រុមការងារជំនាញ ដែលស្ថិតនៅក្រោម COST ។

ដើម្បីធ្វើឱ្យមានភាពស្របគ្នា និងមានប្រសិទ្ធិភាពនៃកិច្ចដំណើរការការងាររបស់ COST សកម្មភាពមួយចំនួនដូចខាងក្រោមត្រូវបានស្នើឡើង៖

**១. ប្របាច់បញ្ចូលគ្នានូវក្រុមប្រឹក្សាយោបល់ ABAPAST និង ABASF ឱ្យទៅជាគណៈប្រឹក្សាយោបល់ទៅឱ្យ COST (Board of Advisers to COST-BAC)៖**

គឺជាតម្រូវការមួយក្នុងកិច្ចប្រឹងប្រែងសម្របសម្រួលការអនុវត្តកម្មវិធី និងគម្រោងទាំងឡាយដែលបានឯកភាពនៅក្នុងផែនការសកម្មភាពអាស៊ាន APASTI រួមទាំងការគាំទ្រផ្នែកថវិកាដែលអាចផ្ដល់ដោយមូលនិធិអាស៊ានផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ (ASTIF) ។ TOR របស់ក្រុមប្រឹក្សាយោបល់ ABAPAST និង ABASF អាចធ្វើការបញ្ចូលគ្នា និងអាចឱ្យ BAC អនុវត្តបាន ។

**២.ធ្វើការរំលាយ កម្លាំងជំនាញបច្ចេកទេសផ្ដល់ដំណឹងជាមុនអំពីព្យុះបែបស៊ូណាមិ (Technical Task Force on Tsunami Warning - TTF-TW) និងក្រុមការងារបច្ចេកទេសផ្នែកម៉ាស៊ីនថាមពលនុយក្លេអែរ (Technical Working Group on Nuclear Power Plant – TWG-NPP)** ហើយក្នុងការងារនេះ អនុគណៈកម្មការ SCMG និង SCSER អាចធ្វើការទទួលយកបាននូវមុខងារ និងភារកិច្ចរបស់ក្រុមការងារនីមួយៗរៀងខ្លួន ។

រចនាសម្ព័ន្ធថ្មីដែលបានស្នើឡើងសម្រាប់កិច្ចសហប្រតិបត្តិការអាស៊ានផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា

Fig. 2 - Proposed Structure of ASEAN cooperation in S&T




### ៣.ការបង្កើតកម្រង (Clusters) និងយន្តការសម្របសម្រួល

អនុគណៈកម្មការនីមួយៗរបស់ COST ត្រូវបានធ្វើការពិនិត្យឡើងវិញ និងកំណត់ឡើងវិញនូវកម្មវត្ថុ និងវិស័យអាទិភាពរបស់គេ ដើម្បីឱ្យត្រូវគ្នាទៅនឹងគោលដៅរបស់ផែនការសកម្មភាពអាស៊ានផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ (APASTI) ។ ដោយចាត់ទុកថាផែនការសកម្មភាព APASTI នឹងមានកម្មវិធីទាំងឡាយដែលឆ្លើយតបទៅនឹង Thematic Tracks នៃកិច្ចផ្តួចផ្តើមក្រាប៊ី (KI) ដែលនឹងមានដាក់បញ្ចូលក្នុងនោះ នូវកម្មវិធី Flagship Programmes របស់ COST នោះចាំបាច់អនុគណៈកម្មការពាក់ព័ន្ធទាំងអស់ ត្រូវចាប់ដៃគ្នាក្នុងការសម្របសម្រួលកិច្ចខិតខំប្រឹងប្រែងរបស់គេ ឆ្ពោះទៅសម្រេចបាននូវលទ្ធផលជាទីពេញចិត្ត។

ដើម្បីដាក់ឱ្យអនុវត្តនូវកិច្ចផ្តួចផ្តើមក្រាប៊ី (KI) នៅថ្ងៃទី២៨-២៩ ខែវិច្ឆិកា ឆ្នាំ២០១២ នៅទីក្រុង Jerudong ប្រទេសប្រ៊ុយណេ សិក្ខាសាលារបស់ក្រុមប្រឹក្សា យោបល់ ABAPAST បានធ្វើឡើងដោយបានផ្តល់អនុសាសន៍ថាគួរដាក់អនុគណៈកម្មការដែលពាក់ព័ន្ធឱ្យនៅក្នុងកម្រង ទៅតាម Thematic Tracks របស់ KI ដូចខាងក្រោម៖

**កម្រងទី១៖** បច្ចេកវិទ្យាបៃតង បច្ចេកវិទ្យាទឹក និងសន្តិសុខម្ហូបអាហារ (សន្តិសុខស្បៀង)

**កម្រងទី២៖** វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍សម្រាប់ជីវភាពរស់នៅ និងទីផ្សារសកល

**កម្រងទី៣៖** សេដ្ឋកិច្ចវេខបនីយកម្ម

**កម្រងទី៤៖** ពិពិធកម្មថាមពល និងជីវៈចម្រុះ ។

### ៤.ការជ្រើសរើសប្រធាន COST និងអង្គភាពក្រោមឱវាទ COST

ដំណើរការការងាររបស់ COST និងអង្គភាពក្រោមឱវាទ អាស្រ័យទៅលើការពន្យារអណត្តិនៃការដឹកនាំរបស់ប្រធានគណៈកម្មាធិការ COST និងអង្គភាពក្រោម COST ក៏ដូចជាថវិកាដែលប្រទេសសមាជិកអាស៊ាន និងលេខាធិការដ្ឋានអាស៊ានបានផ្តល់ឱ្យ ។ នៅពេលដែលផែនការសកម្មភាពអាស៊ានផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ២០០៧-២០១១ (APAST 2007-2011) ត្រូវបានដាក់ចេញច្បាស់នូវតួនាទី និងការទទួលខុសត្រូវតាមការរំពឹងទុក តួនាទីរបស់ប្រធានច្រើនមានដែនកំណត់ក្នុងការធ្វើជាអធិបតីក្នុងកិច្ចប្រជុំ ។ កាលណាមានភាពលំបាកក្នុងការផ្តល់ភាពជាអ្នកដឹកនាំ នោះគំនិតផ្តួចផ្តើម ការដឹកនាំ ការមើលខុសត្រូវការអនុវត្តផែនការសកម្មភាពដែលបាន

កំណត់រួចនៅក្នុងអណត្តិជាប្រធាន ពិតជាមិនអាចសម្រេចបានទាំងស្រុងនោះទេ ។

ក្នុងការជ្រើសរើសប្រធានគណៈកម្មាធិការអាស៊ានផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា (COST) និងប្រធានអនុគណៈកម្មការ ឬអង្គភាពក្រោម COST ជម្រើសមួយចំនួនត្រូវបានយកមកពិចារណា ដូចខាងក្រោម៖

**ជម្រើសទី១៖**

សម្រេចបន្តការជ្រើសរើសតួនាទីជាប្រធានគណៈកម្មាធិការអាស៊ាន COST និងប្រធានអនុគណៈកម្មការ (Sub-Committees) ឬអង្គភាពក្រោម COST ដែលបានផ្ទេរទៅតាមលំដាប់តួអក្សររបស់ប្រទេសសមាជិកអាស៊ាន ដោយឈរលើគោលការណ៍ចែករំលែកស្មើគ្នានូវកាលានុវត្តភាព និងការទទួលខុសត្រូវ ដូចបានចែងនៅក្នុងផែនការសកម្មភាពអាស៊ានផ្នែកវិទ្យាសសាស្ត្រ និងបច្ចេកវិទ្យាឆ្នាំ ២០០៧-២០១១ (APAST 2007-2011) ។

**ជម្រើសទី២៖**

តួនាទីជាប្រធានគណៈកម្មាធិការអាស៊ាន COST និងប្រធានអនុគណៈកម្មការ (Sub-Committees) ឬអង្គភាពក្រោម COST ត្រូវកំណត់យក ទៅតាមសមត្ថកិច្ច និងគុណសម្បត្តិដែលមាន គិតរួមទាំងការសម្រេចរបស់ស្ថាប័នពាក់ព័ន្ធនៃប្រទេសសមាជិកអាស៊ាន ក្នុងការផ្តល់ការគាំទ្រផ្នែកបច្ចេកទេស និងភស្តុភារដល់បេក្ខភាពដែលត្រូវតែងតាំង ។

## VI.ការចល័តធនធានដើម្បីអនុវត្តផែនការសកម្មភាពអាស៊ាន ផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ឆ្នាំ២០១៦-២០២៥ (APASTI 2016-2025)

### ក) មូលនិធិវិទ្យាសាស្ត្រអាស៊ាន (ASF)

មូលនិធិវិទ្យាសាស្ត្រអាស៊ាន (ASEAN Science Fund-ASF) ដែលពីមុនហៅថាមូលនិធិ ASEAN Trust Fund ត្រូវបានបង្កើតឡើងដោយរដ្ឋមន្ត្រីវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាអាស៊ាន នៅខែមករា ឆ្នាំ១៩៨៩ ដោយមានការចូលរួមថវិកាចំនួន ៥០.០០០ ដុល្លា ពីប្រទេសមួយៗដែលជាសមាជិកអាស៊ាន និងការចូលរួមវិភាគទានប្រមាណ ៥៨.២១៨,៦៥ ដុល្លា ពីរដ្ឋាភិបាលប្រទេស New Zealand ។

ដើម្បីពង្រឹងមូលនិធិវិទ្យាសាស្ត្រអាស៊ាន (ASF) នៅក្នុងកិច្ចប្រជុំលើកទី១ថ្នាក់រដ្ឋមន្ត្រីវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាអាស៊ាន ថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០០ មានការរៀបចំនូវកិច្ចព្រមព្រៀងមួយ ដែលគូសបញ្ជាក់ថាប្រទេសសមាជិកអាស៊ានទាំងអស់ត្រូវបង្កើនការដាក់ថវិកាចូលក្នុងមូលនិធិ ASF រហូតដល់១លាន ដុល្លាសហរដ្ឋអាមេរិក ហើយប្រទេសទាំងអស់ត្រូវបង់ថវិការៀងរាល់ឆ្នាំ ចូលក្នុងមូលនិធិ ASF ឱ្យបានគ្រប់ចំនួនរយៈពេល១០ ឆ្នាំ ។

កិច្ចព្រមព្រៀងស្តីពីការបង្កើនថវិការ ASF បានបញ្ជាក់ពីសេចក្តីណែនាំ និងគោលការណ៍ទូទៅ សម្រាប់ដំណើរការមូលនិធិ ASF ។ នៅពេលនោះ ក្រុមប្រឹក្សាផ្តល់យោបល់លើមូលនិធិវិទ្យាសាស្ត្រអាស៊ាន (ABASF) ក៏ត្រូវបានបង្កើតឡើង ដើម្បីផ្តល់ការប្រឹក្សាដល់គណៈកម្មាធិការអាស៊ានផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា អំពីបញ្ហាទាក់ទងនឹងការគ្រប់គ្រងមូលនិធិ ASF ផ្អែកតាម TOR ។ សេចក្តីណែនាំដែលបានចែងសម្រាប់ ASF បានគូសបញ្ជាក់ថា ៨០% នៃចំណូលដែលបានពី Capital Account អាចត្រូវបានប្រើប្រាស់ដើម្បីគាំទ្រដល់សកម្មភាពគម្រោងដែលឯកភាពដោយគណៈកម្មាធិការអាស៊ានផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា (COST) ឯ ២០% ទៀតនៃចំណូលដែលបាន ត្រូវរក្សាឱ្យមាននៅក្នុង Capital Account ។ ដោយសារ បរិមាណថវិកាមានភាពតិចតួច សេចក្តីណែនាំក៏បានបញ្ជាក់បន្ថែមទៀតថា មូលនិធិវិទ្យាសាស្ត្រអាស៊ានអាចត្រូវបានប្រើប្រាស់តែក្នុងករណីដូចខាងក្រោម៖

- ការសិក្សាពីវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា គិតរួមទាំងការរៀបចំកិច្ចប្រជុំ និងជួលអ្នកជំនាញការសម្រាប់ការសិក្សានេះ
- ការផ្លាស់ប្តូរ និងផ្សព្វផ្សាយព័ត៌មានអំពីវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ។

បន្តមក ដោយមានសំណើពីអនុគណៈកម្មការជំនាញផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា (Sub-Committees) សុំឱ្យប្រើប្រាស់មូលនិធិ ASF សម្រាប់សកម្មភាពផ្សេងទៀត ក្រៅពីចំណុចទាំងពីរ ខាងលើ ។

នៅក្នុងកិច្ចប្រជុំលើកទី៥៦ របស់គណៈកម្មការអាស៊ានផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ថ្ងៃទី០៣-០៥ ខែវិច្ឆិកា ឆ្នាំ២០០៨ នៅទីក្រុង Kuching ប្រទេសម៉ាឡេស៊ី មានការសម្រេចឯកភាពលើវិសោធនកម្ម សេចក្តីណែនាំនៃមូលនិធិ ASF ដែលបានអនុញ្ញាតឱ្យប្រើប្រាស់មូលនិធិ ASF ដែលសព្វថ្ងៃមានឈ្មោះថា ASTIF សម្រាប់សកម្មភាពដូចខាងក្រោម៖

ក) ការបង្កើត ឬការពង្រឹងសមត្ថភាពធ្វើគោលនយោបាយសម្រាប់ការងារវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា

ខ) ការផ្លាស់ប្តូរបទពិសោធន៍ និងព័ត៌មានអំពីវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា

គ) ការបង្កើត និងពង្រឹងគ្រឿងចក្រ គ្រឿងម៉ាស៊ីន និងសេវាកម្មដែលត្រូវការចាំបាច់សម្រាប់អនុវត្តដំណើរការអភិវឌ្ឍវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា

ឃ)ការបង្កើត ឬការពង្រឹងសមត្ថភាពជាតិសម្រាប់ធ្វើការវាយតម្លៃ ការជ្រើសរើស ការទទួលបាន និងការទទួលយកបច្ចេកវិទ្យា និងបទពិសោធន៍បរទេស និងសម្របសម្រួលការផ្ទេរបច្ចេកវិទ្យាខាងក្នុងអាស៊ាន និងពីខាងក្រៅប្រទេស

ង) ការអភិវឌ្ឍបច្ចេកទេសដើម្បីតាមដាន និងត្រួតពិនិត្យសកម្មភាពវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា និងវាយតម្លៃឥទ្ធិពលរបស់វា រួមទាំងឥទ្ធិពលអវិជ្ជមាន ទៅលើដំណើរការអភិវឌ្ឍ

ច) បង្កើត និងធ្វើឱ្យប្រសើរឡើងនូវមជ្ឈមណ្ឌល ប្រព័ន្ធ និងបណ្តាញទំនាក់ទំនងព័ត៌មានថ្នាក់តំបន់ ដើម្បីឆ្លើយតបទៅនឹងតម្រូវការប្រទេសអាស៊ាន

ឆ) ការដាក់ឱ្យអនុវត្ត ដាក់ឱ្យដំណើរការសាកល្បង ការធ្វើតេស្ត និងការធ្វើឱ្យសាយភាយ (បាចសាច) នវានុវត្តន៍បច្ចេកវិទ្យា

ជ) ការការពារ និងការប្រើប្រាស់ប្រកបដោយចីរភាពនូវធនធានធម្មជាតិ សម្រាប់ការអភិវឌ្ឍជាតិ និងតំបន់

ឈ) ការអនុវត្តគម្រោងស្រាវជ្រាវ និងអភិវឌ្ឍដែលមានហានិភ័យខ្ពស់ និងមានសក្តានុពលចំណូលពីការវិនិយោគ (Return on Investment-ROI)

ញ)កម្មវិធីអភិវឌ្ឍន៍ធនធានមនុស្សនៅក្នុងការអភិវឌ្ឍវិទ្យាសាស្ត្រក្នុងបណ្តាប្រទេសជឿនលឿន ។

សេចក្តីណែនាំថ្មីសម្រាប់កិច្ចដំណើរការមូលនិធិវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ (ASTIF) និងការដាក់បំពេញថវិកាមូលនិធិត្រឹមខែមិថុនា ឆ្នាំ២០១៥ អាចចាត់ទុកថាគ្រប់គ្រាន់សម្រាប់ពេលនេះ ក្នុងការគាំទ្រសកម្មភាពផ្តួចផ្តើមផែនការសកម្មភាពអាស៊ានផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ដែលនឹងត្រូវការថវិកាសមរម្យនោះ ។ គណៈកម្មាធិការអាស៊ាន COST អាចពិចារណាក្នុងការអំពាវនាវជាថ្មីរកថវិកាមូលនិធិ ASTIF ដែលមានសមតុល្យបច្ចុប្បន្នប្រហាក់ប្រហែល (ប្រមាណ ៥លាន ដុល្លា) ។ ក្រុមប្រឹក្សាយោបល់ដល់ COST (BAC) នឹងអាចធ្វើការរៀបចំលក្ខណៈវិនិច្ឆ័យ ដែលកំណត់នូវគម្រោង ឬកម្មវិធី STI ដែលអាចរកបាន និងស្វែងរកបាននូវការគាំទ្ររបស់មូលនិធិ ASTIF ។

គម្រោងដែលទទួលបានការឯកភាពហើយ (Approved projects) ត្រូវរួមបញ្ចូលនូវផែនការថវិកាលំអិតគ្រប់ចំណុចដែលនឹងត្រូវចំណាយ និងកាលបរិច្ឆេទនៃការទទួលថវិកាដើម្បីអនុវត្ត (បើសិនជាមាន) ។ ថវិកាដែលទទួលបានចែកចេញជា២ ផ្នែក ដូចខាងក្រោម៖

1. **ចំណាយសម្រាប់ចាត់ចែងគ្រប់គ្រង និងចំណាយមូលធន៖**

   ចំណាយនេះនឹងរួមបញ្ចូលនូវចំណាយទាំងអស់សម្រាប់ចាត់ចែងគ្រប់គ្រង មានដូចជា ការជួល សម្ភារៈបរិក្ខា ការិយាល័យ ចំណាយដែលត្រូវការចាំបាច់ ប្រាក់ខែបុគ្គលិកសេវាកម្មក្នុងស្រុកដែលបានជួល ការបង់

ថ្លៃជានាក់ប់រង ព្រមទាំងចំណាយសម្រាប់ថ្លៃដី និងអគារ ។

2. **ចំណាយសម្រាប់ប្រតិបត្តិ**

ជាចំណាយទាំងអស់ក្រៅពីចំណាយខាងលើ រួមមានតម្លៃរៀបចំកម្មវិធី ចំនាយសំរាប់ការជ្រើសរើសបុគ្គលិកគម្រោង ថ្លៃសេវាកម្ម និងប្រាក់ហោប៉ៅរបស់បុគ្គលិកជំនាញឯកទេស ដែលនឹងធ្វើការក្នុងគម្រោងដែលបានឯកភាពយល់ព្រមរួច ។

ថវិកាមូលនិធិ ASTIF អាចត្រូវបានផ្តល់ឱ្យសម្រាប់តែការចំណាយសម្រាប់ប្រតិបត្តិរបស់គម្រោងដែលមានការឯកភាពយល់ព្រមប៉ុណ្ណោះ លើកលែងតែគម្រោងដែលមានទាក់ទងនឹងការច្នៃប្រឌិត-បង្កើតថ្មី (Innovation) ដែលចំណាយមូលធន អាចត្រូវបានពិចារណាក្នុងការជួយឧបត្ថម្ភ ។

សម្រាប់គម្រោងដែលទទួលបានការឯកភាពរួច (គម្រោងដែលនឹងទទួលថវិកាតែមួយដង) ទឹកប្រាក់ប្រហាក់ប្រហែលនឹងបរិមាណដែលបានឯកភាព នឹងត្រូវបានផ្តល់ជូនទៅលេខាធិការដ្ឋានជាតិ នៃគណៈកម្មាធិការអាស៊ាន COST (ASEAN-COST National Secretariat) ឬស្ថាប័នជាតិដែលត្រូវបានចាត់តាំងដោយរដ្ឋាភិបាលដែលហៅថា Project Proponent ក្នុងអំឡុង៣០ ថ្ងៃ មុនពេលចាប់ផ្តើមដំណើរការគម្រោង ហើយ ត្រូវ Project Proponent ត្រូវធ្វើលិខិតទៅលេខាធិការដ្ឋានអាស៊ានបញ្ជាក់ថាបានទទួលថវិកាគម្រោងហើយ ។

ចំពោះគម្រោងផ្សេងពីគម្រោងខាងលើ ការផ្តល់ថវិការគម្រោងនឹងត្រូវធ្វើឡើងទៅតាមដំណាក់ការ ហើយការផ្តល់ថវិកានៃដំណាក់ការនីមួយៗ ត្រូវធ្វើឡើង៦០ ថ្ងៃ មុនពេលចាប់ផ្តើមដំណើរការគម្រោងតាមដំណាក់ការនោះ ។ ក្នុងករណីដែលថវិកាគម្រោងមិនត្រូវបានប្រើប្រាស់អស់ទេនោះ អ្នកដែលទទួលថវិកាពី ASTIF (Project Proponent) ត្រូវផ្តល់ដំណឹងដល់លេខាធិការដ្ឋានអាស៊ាន ដើម្បីបង្វិលចំណែកថវិកានៅសល់ ឬទាំងស្រុងទៅឱ្យ ASTIF វិញ ។

ចំពោះគម្រោងដែលរយៈពេលអនុវត្តច្រើនជាង ៦ខែ អ្នកដែលទទួលថវិកាពី ASTIF ឬហៅថា Project Proponent ត្រូវផ្តល់របាយការណ៍វឌ្ឍនភាពគម្រោងរយៈ៦ ខែ នៃការអនុវត្តសកម្មភាពគម្រោង រួមទាំងស្ថានភាពថវិកាគម្រោង (Financial Statement) ជូនទៅគណៈកម្មាធិការអាស៊ានផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា (ASEAN COST) តាមរយៈក្រុមប្រឹក្សាយោបល់ទៅឱ្យ COST (BAC) នៅថ្ងៃទី៣១ ខែកក្កដា ឬថ្ងៃទី៣១ ខែមករា។ នៅចុងបញ្ចប់នៃគម្រោង Project Proponent ត្រូវផ្តល់របាយការណ៍បញ្ចប់គម្រោង (Project completion report) ជូនទៅគណៈកម្មាធិការអាស៊ានផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា (ASEAN COST) តាមរយៈក្រុមប្រឹក្សាយោបល់ BAC មិនលើសពី៣០ ថ្ងៃ ក្រោយពីថ្ងៃបញ្ចប់គម្រោង ។ របាយការណ៍បញ្ចប់គម្រោងត្រូវរួមបញ្ចូលទាំងរបាយការណ៍ស្ថានភាពនៃការចំណាយថវិកាគម្រោង ដែលនឹងត្រូវបានធ្វើអធិការកិច្ចដោយក្រុមអធិការកិច្ចរបស់រដ្ឋ ។

**<u>ខ) មូលនិធិអភិវឌ្ឍន៍អាស៊ាន (ADF)</u>**

កិច្ចព្រមព្រៀងក្នុងការបង្កើតមូលនិធិអភិវឌ្ឍន៍អាស៊ាន (ADF) ត្រូវបានចុះហត្ថលេខាដោយថ្នាក់ដឹកនាំអាស៊ាននៅថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០០៥ នៅទីក្រុងវៀងច័ន្ទប្រទេសឡាវ ។ TOR របស់ ADF ត្រូវបានបង្កើតឡើងដើម្បីគាំទ្រដល់សកម្មភាពផ្តួចផ្តើមរបស់កម្មវិធី Vientiane Action Programme (VAP) ។ ប្រទេសសមាជិកអាស៊ានបានឯកភាពចូលរួមវិភាគទាន ១លាន ដុល្លា ទៅក្នុងមូលនិធិ ADF ។ មូលនិធិអភិវឌ្ឍន៍អាស៊ានបានជំនួសមូលនិធិអាស៊ាន (ASEAN Fund-AF) ដែលបានបង្កើតនៅថ្ងៃទី១៧ ខែធ្នូ ឆ្នាំ១៩៦៩ ។

បន្ទាប់មក TOR របស់មូលនិធិអភិវឌ្ឍន៍អាស៊ាន ត្រូវបានធ្វើវិសោធនកម្ម ហើយត្រូវបានឯកភាពទទួលយកដោយគណៈកម្មការតំណាងអចិន្ត្រៃយ៍ Committee of Permanent Representatives (CPR) នៅថ្ងៃទី២២ ខែតុលា

ឆ្នាំ២០១៣ ។ វិសោធនកម្ម TOR បានបញ្ជាក់ថាមូលនិធិ ADF ត្រូវបានប្រើប្រាស់ក្នុងគោលបំណងណាមួយដូចខាងក្រោម៖

(i) ស្វែងរកការផ្តល់មូលនិធិពីដៃគូអភិវឌ្ឍន៍ និងដៃគូផ្សេងទៀត សម្រាប់កម្មវិធី និងគម្រោងកិច្ចសហប្រតិបត្តិការ ថ្នាក់តំបន់ ។ នៅពេលប្រើប្រាស់បដិភាគ ទឹកប្រាក់មិនលើសពី២០% នៃបរិមាណសរុបដែលបានលើកឡើង ដោយមិនគិតពីប្រភពនៃការចូលរួមមូលនិធិ ជាប្រទេសសមាជិកអាស៊ាន ឬពីភាគីខាងក្រៅ

(ii) ផ្តល់នូវមូលនិធិបឋម Seed Funding សម្រាប់សកម្មភាពផ្តួចផ្តើមនៃគម្រោងធំៗ ដែលត្រូវការការគាំទ្រថវិកាពីដៃគូចរចារ ឬដៃគូពីខាងក្រៅផ្សេងទៀត

(iii) ផ្តល់ការគាំទ្រថវិកាទាំងស្រុងទៅលើគម្រោងតូចៗ និងរយៈពេលខ្លី ដែលទទួលបានការទុកចិត្ត ។

មូលនិធិអភិវឌ្ឍន៍អាស៊ាន ADF នឹងជួយដល់គម្រោង និងសកម្មភាពទាំងឡាយ ដែលកំណត់ច្បាស់នូវគោលបំណង និងក្រុមគោលដៅ ព្រមទាំងមានបញ្ជាក់ពេលវេលាជាក់លាក់សម្រាប់អនុវត្ត ។

មុខចំណាយនៅក្នុងគម្រោងថវិកាត្រូវបានចាត់ថ្នាក់ជា៣ ប្រភេទដូចខាងក្រោម៖

- **ចំណាយសម្រាប់រដ្ឋបាល** មានដូចជាការជួល បរិក្ខា និងទីកន្លែងការិយាល័យ ប្រាក់បៀវត្សរបស់បុគ្គលិកក្នុងស្រុក ការធានារ៉ាប់រង និងពន្ធអាករ
- **ចំណាយប្រតិបត្តិ** មានប្រាក់ចំណាយផ្សេងៗ ចំណាយសម្រាប់ការជ្រើសរើស ប្រាក់ទូទាត់ប៉ះប៉ូវអ្នកជំនាញក្នុងស្រុកដែលចូលរួមក្នុងគម្រោង និងចំណាយពាក់ព័ន្ធផ្សេងទៀត (ឧ. ថ្លៃធ្វើដំណើរ ស្នាក់នៅ ប្រាក់ហោប៉ៅ) ឧបករណ៍ និងការផ្គត់ផ្គង់
- **ចំណាយមូលធន** មានថ្លៃដី និងអគារ តម្លៃបរិក្ខាដែលច្រើនជាង ១០.០០០ ដុល្លា ។

នៅក្នុងនេះ មានតែ**ចំណាយប្រតិបត្តិសម្រាប់គម្រោងប៉ុណ្ណោះ** ដែលអាចទទួលបានការគាំទ្រពីមូលនិធិអភិវឌ្ឍអាស៊ាន ។ ចំណែកឯ ចំណាយសម្រាប់រដ្ឋបាល និងចំណាយមូលធន ជាបន្ទុករបស់រដ្ឋាភិបាលដែលអនុវត្តគម្រោង ។ ចំពោះចំណាយថ្លៃធ្វើដំណើរ ស្នាក់នៅ និងចំណាយផ្សេងទៀតរបស់តំណាងចូលរួមក្នុងកិច្ចប្រជុំរបស់អាស៊ាន នឹងមិនត្រូវបានចាត់ទុកថាជាបន្ទុកចំណាយដោយមូលនិធិអភិវឌ្ឍន៍អាស៊ានទេ ។

## VII.ការចាត់ចែងអនុវត្ត និងការពិនិត្យឡើងវិញ នូវផែនការសកម្មភាពអាស៊ានផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ឆ្នាំ២០១៦-២០២៥ (APASTI 2016-2025)

### <u>ការអនុវត្ត</u>

កិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាអាស៊ាន (AMMST) ត្រូវទទួលបន្ទុកពិនិត្យមើលការអនុវត្តទូទៅនៃ APASTI 2016-2025 ។ រីឯគណៈកម្មាធិការអាស៊ានផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា (COST) ត្រូវទទួលខុសត្រូវក្នុងការដាក់ឱ្យដំណើរការ និងបំលែងគោលបំណងជាយុទ្ធសាស្ត្រ (Strategic thrusts) ឱ្យទៅជាសកម្មភាពជាក់លាក់ ។

ក្រុមប្រឹក្សាយោបល់ឱ្យ COST (BAC) ត្រូវដឹកនាំផែនការសកម្មភាពលំអិតសម្រាប់អនុវត្ត APASTI 2016-2025 រួមទាំងការកំណត់លក្ខណៈវិនិច្ឆ័យសម្រាប់ជ្រើសរើសគម្រោង ដែលអាចគាំទ្រដោយមូលនិធិវិទ្យាសាស្ត្របច្ចេកវិទ្យា និងនវានុវត្តន៍ (ASTIF) ។

អនុគណៈកម្មការនីមួយៗត្រូវរៀបចំកម្មវិធីការងាររៀងខ្លួន (Work programmes) ដែលនឹងមានទិសដៅ គោលដៅ និងយុទ្ធសាស្ត្រច្បាស់លាស់នៅក្នុងការអនុវត្តសកម្មភាពជាក់លាក់ ដែលត្រូវគ្នាទៅនឹងវិស័យជាអាទិភាពរបស់គេ គោលដៅ និងគោលបំណងជាយុទ្ធសាស្ត្ររបស់ APASTI 2016-2025 ។

**<u>ការតាមដាន និងត្រួតពិនិត្យ</u>**

ការអនុវត្តផែនការសកម្មភាពអាស៊ានផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍២០១៦-២០២៥ ត្រូវបានតាមដានត្រួតពិនិត្យ និងវាយតម្លៃ ដោយទៀងទាត់ទៅតាមសេចក្តីណែនាំបច្ចេកទេស និងលក្ខណៈវិនិច្ឆ័យ ដែលរៀបចំឡើងដោយក្រុមប្រឹក្សាយោបល់ឱ្យ COST (BAC) ។ ប្រព័ន្ធតាមដានត្រួតពិនិត្យផ្តោតលើការអនុវត្តសកម្មភាព ដែលរៀបចំដោយលេខាធិការដ្ឋានអាស៊ាន ដើម្បីតាមដានវាយតម្លៃការអនុវត្ត ASCC Blueprint អាចត្រូវបានចាត់ទុកថាជាយន្តការដ៏ល្អមួយ ។ អនុគណៈកម្មការត្រូវធ្វើការវាយតម្លៃប្រសិទ្ធភាព និងប្រសិទ្ធិផលនៃការអនុវត្តកម្មវិធីការងាររបស់គេ ។ ការពិនិត្យឡើងវិញជាផ្លូវការនូវការអនុវត្តផែនការសកម្មភាព APASTI 2016-2025 នឹងធ្វើឡើងនៅឆ្នាំ២០២០ និងឆ្នាំ២០២៥ ជាបន្តបន្ទាប់ ។

--------------------